# មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្ភាសន៍ជាមួយ រុន ភឹម ភេទប្រុស កើតឆ្នាំ ១៩៥៧

## មុខងារសម័យខ្មែរក្រហមៈ“កម្មករជាកៅស៊ូនៅស្នួល”

## ស្រុកកំណើតនៅភូមិតាពុន ឃុំស្វាយជ្រះ ស្រុកស្នួល ខេត្តក្រចេះ

## សព្វថ្ងៃរស់នៅភូមិទួលប្រាសាទ ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ

## ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៣

## សម្ភាសន៍ដោយៈ ឌី ខាំបូលី និង ម៉ម សុវណ្ណ

## ០១:៥៧ :៥៨

## ៥៦ ទំព័រ

សុវណ្ណៈ ជំរាបសួរ ដំបូងខ្ញុំសូមណែនាំខ្លួនឲ្យស្គាល់ ខ្ញុំឈ្មោះសុវណ្ណ គាត់ខាងនេះឈ្មោះបងបូលី ហើយមកថ្ងៃនេះ គឺពួកខ្ញុំធ្វើការនៅខាងស្រុកត្រពាំងប្រាសាទណាពូ ដោយសារតែស្រុកត្រពាំងប្រាសាទនិង អន្លង់វែងតស៊ូជាមួយខាងវៀតណាម ជាមួយខាងរដ្ឋាភិបាលណាពូ ។ ពួកខ្ញុំចុះមកធ្វើការចងក្រង និងប្រមែលប្រមូលឯកសារ ពាក់ព័ន្ធជាមួយធ្លាប់ឆ្លងកាត់នៅរបបពីមុនមក ចឹងតំបន់នេះពីមុនមកដើម្បី សរសេរជាសៀវភៅមួយដែលមានឈ្មោះមគ្គុទេសអន្លង់វែងណាពូ សៀវភៅជាសៀវភៅចងក្រងដើម្បីផ្សព្វផ្សាយដើម្បីភ្ញៀវជាតិ និងអន្តរជាតិស្គាល់អន្លង់វែង និងស្គាល់ត្រពាំងប្រាសាទពីមុនដែរ ។ អាចថាចាត់ទុកជាតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រមួយ នៅក្នុងប្រទេសកម្ពុជាយើង ពីតំបន់ផ្សេងៗទៀត ហើយក៏ជាការចងក្រងមុនទុកឲ្យក្មេងៗ ជំនាន់ក្រោយ គេបានស្គាល់គេបានឮរឿងរ៉ាវអន្លង់វែង ត្រពាំងប្រាសាទដែរពូ ។ ចឹងខ្ញុំគ្រាន់ តែចង់ដឹងរឿងរ៉ាវរបស់ពូឆ្លងកាត់តាំងពីក្មេងរហូតដល់ពេលបច្ចុប្បន្នវាយ៉ាងម៉េចដែរ ។ ចឹងដំបូង ខ្ញុំចង់ឲ្យពូណែនាំខ្លួន ពូឈ្មោះអីគេ?

ភឹមៈ រុន ភឹម ។

សុវណ្ណៈ ពូសព្វថ្ងៃ អាយុប៉ុន្មានដែរ?

ភឹមៈ អាយុហាប៉ុន្មាន! ខ្ញុំកើតឆ្នាំណា ។

សុវណ្ណៈ ពូកើតឆ្នាំណាដែរ?

ភឹមៈ ឆ្នាំ១៩៥៧!

សុវណ្ណៈ ១៩៥៧ ។ ចឹងពូសព្វថ្ងៃ ពូប្រកបរបរអីគេ?

ភឹមៈ ធ្វើស្រែចម្ការណាអូន ។

សុវណ្ណៈ ធ្វើស្រែចម្ការ ។ ប៉ុន្តែភាគច្រើន ពូធ្វើស្រែ ឬធ្វើចម្ការ?

ភឹមៈ ចម្ការក៏ធ្វើ ស្រែក៏ធ្វើ ។

សុវណ្ណៈ  ចម្ការធ្វើពីខែណា ដល់ខែណា?

ភីមៈ  ខ្ញុំដាំដំឡូងតាំងពីខែ៨ ។

សុវណ្ណៈ  ខែ៨ ចឹងដល់ខែណា?

ភីមៈ  ខែ១២ហ្នឹង (ស្តាប់ពុំបាន)

សុវណ្ណៈ  ចឹងយើងចាប់ផ្តើមខែ៨ ដល់ខែ១២ ប្រមូលផល ។ ហើយយើងលក់ឲ្យគេយ៉ាងម៉េចពូ?

ភីមៈ  ជួនណាគេថាបាន៧០០ មិនទៀតអាដំឡូង ជួនកាល៧០០ជួនកាលទៅ៦០០, ៦៣០, ៦៤០ ទៅតាមតែគេថាណា៎ ។

សុវណ្ណៈ  គេខាងណាមកទិញពូ ឈ្មួញខាងណាគេមកទិញ?

ភីមៈ  ឈ្មួញខាងណា ខ្ញុំមិនសូវដឹងទេណា ព្រោះច្រើនពេកនោះ ។

សុវណ្ណៈ  ឈ្មួញអ្នកខាងក្នុង ឬខាងក្រៅគេមក?

ភីមៈ  មិនដឹងខាងណា ភាគច្រើនយកទៅថៃណា ឮថាបើទៅខាងវៀតណាមនោះវាកោ បើទៅថៃវិញវាអត់កោទេ ខ្ញុំមិនដឹងដែរណា ចេះតែដើរទិញទៅ ។

សុវណ្ណៈ  ហើយតម្លៃយ៉ាងម៉េច គេឲ្យយើងទៅតាម ផលដែលយើងប្រមូលច្រើន ឬក៏ផលដែលយើងប្រមូលបានតិចឲ្យថ្លៃ ឬយ៉ាងម៉េច?

ភីមៈ  អត់មានឲ្យថ្លៃ ឲ្យអីទេ ព្រោះខ្ញុំរាប់ឆ្នាំជួនណាទៅបានចង់២០០បេនោះណា ដំឡូង គ្រាន់ថាពីដើមទី យើងបាន៧០០ក៏មានដែរ ដល់មកមួយសារទៀតទៅ ៦៥០, ៥៥០ទៅ តាមតែគេថា វាមិនកំណត់ណា ប៉ុណ្ណឹងឯង ។

សុវណ្ណៈ  នៅក្នុងភូមិហ្នឹង ភាគច្រើនអ្នកភូមិគាត់ រកស៊ីធ្វើអីខ្លះពូ?

ភីមៈ  រកស៊ីមានអីទេ! មានតែធ្វើស្រែ ធ្វើដំឡូងដីវាតិចណា ខ្លះគេទិញទៅ! ខ្លះទៅ១ហាត់ទៅខ្លះអត់ដីទៅ ជួលរបស់គេធ្វើទៅណា ។ ប៉ុន្តែ ខ្ញុំអត់ទេ ខ្ញុំគ្រប់គ្រាន់ដីហើយនោះ ។

សុវណ្ណៈ  ចុះទំនេរពីធ្វើស្រែធ្វើចម្ការហ្នឹង គាត់ធ្វើអីគេ?

ភីមៈ  អត់មាន! គ្មានពេលទំនេរខ្ញុំនោះ ។ ផុតពីស្រែចម្ការហើយចាប់ផ្តើមមើលភ្លឺមើលអីទៅណា ។ វាអត់មានការងារអីទេ ធ្វើចម្ការធ្វើអីហើយនោះ នៅដាំដំឡូង ។

សុវណ្ណៈ  មានបរបាញ់សត្វ ដាក់ទន្ទាក់សត្វអី មានកាប់ឈើកាប់អីខ្លះទេពូ?

ភីមៈ  អត់មានទេ! កាប់ឈើ កាប់អី យើងអារឈើវាវែងៗណា ។

សុវណ្ណៈ  ចុះអ្នករកស៊ីឈើ រកស៊ីអីនោះ?

ភីមៈ  ទេ! អត់មានទេ នៅភូមិនេះគ្មានទេ ។

សុវណ្ណៈ ភូមិនេះគេហៅភូមិអីគេពូ?

ភឹមៈ ភូមិទួលប្រាសាទ ។

សុវណ្ណៈ ឃុំ?

ភឹមៈ ឃុំទំនប់ដាច់ ។

សុវណ្ណៈ ឃុំទំនប់ដាច់ ។ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យមែនទេពូ?

ភឹមៈ បាទ!

សុវណ្ណៈ ចុះពូស្រុកកំណើតពូនៅឯណាដែរ?

ភឹមៈ ស្រុកណើតខ្ញុំនៅស្វាយជ្រះ ។

សុវណ្ណៈ ភូមិអីគេ?

ភឹមៈ ភូមិតាពុន ។

សុវណ្ណៈ ភូមិអីគេ?

ភឹមៈ ភូមិតាពុន ។

សុវណ្ណៈ ភូមិតាពុន! ឃុំអីគេពូ?

ភឹមៈ ឃុំនេះឯង ឃុំស្វាយជ្រះតែម្ដងណា ។

សុវណ្ណៈ ស្រុក?

ភឹមៈ ស្រុក អាដែងស្រុកស្នួល ។

សុវណ្ណៈ ខេត្តក្រចេះពូ?

ភឹមៈ ក្រចេះ ។

សុវណ្ណៈ ពូគ្រួសារពូឈ្មោះអីគេ

ភឹមៈ ទូន រី ។

សុវណ្ណៈ ទូន រី ។ គាត់សព្វថ្ងៃធ្វើអីគេ?

ភឹមៈ ធ្វើស្រែចម្ការនោះហើយ ។

សុវណ្ណៈ ធ្វើស្រែចម្ការដូចគ្នា?

ភឹមៈ បាទ!

សុវណ្ណៈ ហើយពូមានកូនប៉ុន្មាននាក់?

ភឹមៈ កូន៦នាក់ ។

សុវណ្ណៈ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ភីមៈ ប្រុស៥ ស្រី២ ។

សុវណ្ណៈ ប្រុស៥ ស្រីតែ១ទេ ។

ភីមៈ ប្រុស៤ទេ ។

សុវណ្ណៈ ហើយមានគ្រួសារអស់ហើយនៅពូ?

ភីមៈ នៅទេ!

សុវណ្ណៈ នៅទាំងអស់?

ភីមៈ បាទ!

សុវណ្ណៈ ហើយបងគេអាយុប៉ុន្មាន?

ភីមៈ មានមួយបងឆ្នាំខាល ។

សុវណ្ណៈ តែបងនោះស្រី ឬក៏ប្រុស?

ភីមៈ បងគេបង្អស់ ។ ប៉ុន្តែវារន្ទះបាញ់ស្លាប់ទៅហើយ ។

សុវណ្ណៈ ហើយនៅរៀន នៅសូត្រខ្លះទេកូន៦នាក់ហ្នឹង?

ភីមៈ នៅ! នៅតែ១ទេ នៅតែអាពៅ១ ។

សុវណ្ណៈ នៅកូនពៅគេ! នៅរៀនថ្នាក់ទីប៉ុន្មានឥលូវនេះ?

ភីមៈ ទី៤មិនដឹងឥលូវហ្នឹង ។

សុវណ្ណៈ ទី៤! ហើយរៀននៅណាដែរលោកពូ?

ភីមៈ នោះទំនប់ដាច់ ។

សុវណ្ណៈ នៅសាលាបឋមសិក្សាទំនប់ដាច់ហ្នឹងហ៎?

ភីមៈ បាទ!

សុវណ្ណៈ ហើយក្នុងចិត្ត ពូឲ្យកូនទៅរៀនធ្វើអីគេទៅថ្ងៃអនាគត?

ភីមៈ ចង់បណ្ដុះបណ្ដាលឲ្យធ្វើ អាហ្នឹងខ្ញុំមិនកំណត់ទេ បើថាតែគេចង់ទៅផ្លូវទៅផ្លូវនោះទៅ អ៊ូបើថាខ្ញុំចង់ទៅផ្លូវចេះ នេះជារឿងរបស់គេ ខ្ញុំមិនថាអ៊ូបើចង់ថាចេះៗ យើងចំណុះរបស់គេបានឆាប់ចេះណា បើថាទៅរៀនម៉ូតូ ទៅរៀនកង់អី ស្អីផ្សេងៗថាចិត្តខ្ញុំមិនចង់រៀន ក៏ទៅមិនរួច បើចិត្តចំណង់របស់គេបានទៅរួច ។

សុវណ្ណៈ តែចិត្តរបស់ពូចង់ឲ្យកូនធ្វើអីគេ? ធ្វើគ្រូ! ធ្វើទាហាន ធ្វើពេទ្យ ឬក៏ធ្វើបុគ្គលិករបស់រដ្ឋរបស់អង្គការ បុគ្គលិកក្រុមហ៊ុនអី សម្រាប់ពូ ពូចង់ឲ្យកូនធ្វើអីគេនៅថ្ងៃអនាគតទៅ?

ភីមៈ ចង់ឲ្យធ្វើពេទ្យ បានវាគ្រាន់បើតិច ។

សុវណ្ណៈ ម៉េចក៏ចង់ឲ្យកូនធ្វើពេទ្យ?

ភីមៈ បានប្រាក់ចំណូលវាបានខ្លះ! នឹកឃើញថា វាចាំបាច់ បើវាបេះ(ស្តាប់ពុំបាន) ។ បានធ្វើពេទ្យ ទៅបានលក់ថ្នាំ លក់អីទៅ ។ ប៉ុន្តែអានេះស្រេចតែចិត្តវាទេ ចិត្តគេចង់ប៉ុណ្ណាក៏ប៉ុណ្ណឹងទៅ ។

សុវណ្ណៈ ហើយចុះនៅក្នុងស្រុកភូមិ ពេលឈឺថ្កាត់យើងធ្វើយ៉ាងម៉េចទៅពូម្តងៗ?

ភីមៈ នាំគ្នាទៅពេទ្យទៅ ។

សុវណ្ណៈ ពេទ្យនៅឯណាដែរទៅ?

ភីមៈ ពេទ្យសម្បត្តិយើងនេះ ។

សុវណ្ណៈ ពេទ្យរដ្ឋ ឬឯកជន?

ភីមៈ ខ្លះទៅពេទ្យរដ្ឋទៅ ហើយខ្លះទៅពេទ្យឯងជនទៅណា ។ ជួនណាថ្នាំតិចទៅ គេទៅទិញពេទ្យនៅកន្លែងវង្វង់ទៅ អាកន្លែងផ្លូវ(ស្តាប់ពុំបាន) ។ ដល់គេទៅៗ បើថាគេ(ស្តាប់ពុំបាន) គេទៅអន្លង់វែងចឹងទៅ ។ ពេទ្យគេ(ស្តាប់ពុំបាន) នៅទីនេះណា បើថាអត់មានអីទេ គេទៅអន្លង់វែង បើមិនកើតអីទេ គេទៅទៀតទៅណា គេបញ្ជូនតទៅណា ។

សុវណ្ណៈ ឈឺធ្ងន់បេះតែបន្តទៅទៀតទៅ?

ភីមៈ បាទ! មិនថាឈឺធ្ងន់ ឈឺស្រាលទេ ។

សុវណ្ណៈ នៅក្នុងភូមិច្រើនតែឈឺអីគេ?

ភីមៈ អត់អីផងមានគ្រុន! អ្នកខ្លះទៅវាឈឺ សំខាន់អាដែងក្រពះ ពោះវៀនលាប់ ។

សុវណ្ណៈ ម៉េចក៏ឈឺក្រពះពោះវៀន?

ភីមៈ អ្នកខ្លះ គេថាទៅហូបរបស់របប អាផ្សារអីទៅ ជាតិគីមីជាតិអី គាត់និយាយចឹង ។

សុវណ្ណៈ ចុះអនាម័យអ្នកស្រុកអ្នកភូមិយ៉ាងម៉េចដែរទៅពូ?

ភីមៈ ចុះមានអីគ្រាន់តែអនាម័យ ។ ផ្ទះខ្ញុំទឹកក្តៅរាល់ពេល អត់មានអីទេ ទឹកក្តៅ ។

សុវណ្ណៈ មានខាងមណ្ឌលសុខភាព គេចុះមកណែនាំប្រាប់ការហូបចុកមានអនាម័យ មានអីខ្លះទេពូ?

ភីមៈ បាទ! ទេ ពួកខ្ញុំឡើងទៅ(ស្តាប់ពុំបាន) បានន័យថាអត់ដឹងណា ។

សុវណ្ណៈ អត់សួរមានខាងអង្គការណា ខាងអង្គការគេចុះមកជួយប្រាប់ទេពូហ៎?

ភីមៈ មានតែគេប្រាប់តាមរាត់ដ្យូ តាមរាត់ដ្យូ តែអនាម័យ អនាអីទៅ តាមហ្នឹងទៅ ។

សុវណ្ណៈ និយាយចឹងពូ មានបងប្អូនប៉ុន្មាននាក់?

ភីមៈ បងប្អូនសរុបអ៎! ៧នាក់ ។

សុវណ្ណៈ ទាំងពូ?

ភឹមៈ បាទ!

សុវណ្ណៈ ប្រុសប៉ុន្មានស្រីប៉ុន្មានពូ?

ភឹមៈ ប្រុស៥ ស្រីតែ២ទេ ។

សុវណ្ណៈ ពូកូនទីប៉ុន្មាន?

ភឹមៈ ខ្ញុំពិបាកថាណាស់ ទីប៉ុន្មានទី១ ទី២ ទី៣ហើយ ។

សុវណ្ណៈ ទី៣ ។ ឪពុកពូឈ្មោះអីគេ?

ភឹមៈ ឈ្មោះ រុន ហ្នឹង ។

សុវណ្ណៈ ស្អីរុន?

ភឹមៈ រុន ភឹម ។

សុវណ្ណៈ ម្ដាយ?

ភឹមៈ យ៉ាន ។

សុវណ្ណៈ យ៉ាន!

ភឹមៈ បាទ!

សុវណ្ណៈ អីគេយ៉ាន?

ភឹមៈ អីទេត្រកូល ឈ្មោះឌុក ។

សុវណ្ណៈ ឌុក យ៉ាន ។ កាលពីមុន គាត់ធ្វើអីគេ?

ភឹមៈ អត់មានធ្វើអីទេ ពីដើម ។

សុវណ្ណៈ ធ្វើតែស្រែចម្ការទៅពូ?

ភឹមៈ បាទ! ធ្វើតែស្រែចម្ការទៅពូ ។

សុវណ្ណៈ ហើយ! កាលហ្នឹង ចុះពេលឥលូវ គាត់នៅរស់ ឬក៏ខូចហើយពូ?

ភឹមៈ ស្លាប់បាប់ហើយហ្នឹង ។

សុវណ្ណៈ ឪពុកស្លាប់ឆ្នាំណា?

ភឹមៈ ឪពុកស្លាប់យូរហើយ តាំងពីសាចុះទៅផ្ដាច់ខ្លួនណា យូរហើយ ជាង២០ឆ្នាំ ហើយមើលទៅ ។

សុវណ្ណៈ ជំនាន់អីគេ?

ភឹមៈ អត់ទេ! មួយជំនាន់យើងណា ។

សុវណ្ណៈ ដិនាន់នេះទេ! ម្ដាយ?

ភឹមៈ ម្ដាយក៏ស្លាប់ដែរ ។

សុវណ្ណៈ ដូចគ្នាដែរ ពូឈប់រៀន ឈប់រៀនថ្នាក់ទីប៉ុន្មាន?

ភឹមៈ ហ៉ូ! កាលហ្នឹង និយាយទៅខ្ញុំអត់ចេះអីទេ ។ កាលហ្នឹង សង្គ្រាម៥ឆ្នាំ! ដល់សង្គ្រាម៥ឆ្នាំ ទៅនៅតូចកាលហ្នឹង ហើយមកសម័យយើងនេះ ចូលយុទ្ធជនយើងបណ្ដោយ ។

សុវណ្ណៈ ចុះពូមានបានទៅសាលាទៅអីខ្លះទេ?

ភឹមៈ ទៅ! ទៅពីយតូចណា(ស្ដាប់ពុំបាន) ។

សុវណ្ណៈ បានរៀន ប៉ុន្មានខែ ប៉ុន្មានឆ្នាំ?

ភឹមៈ ២ ទៅ៣ខែ ទេដឹង ប៉ុណ្ណឹងឯង ។ ដល់ទៅហើយ!

សុវណ្ណៈ ចុះមុនឆ្នាំ៧០ ពូអាយុប្រហែលប៉ុន្មាន? មុនរដ្ឋប្រហារគេទម្លាក់សម្ដេចណាពូ?

ភឹមៈ ទេ! អាយុប៉ុន្មានទេដឹង អាយុទើបតែ១០ទេដឹង ។ ដូចជាពុំសូវដឹងច្បាស់ដែលហ្នឹងណា ។

សុវណ្ណៈ ចុះចូលបដិវត្តន៍ឆ្នាំណាពូ?

ភឹមៈ ខ្ញុំចូល៧៥ ។

សុវណ្ណៈ ចូល៧៥ទេ! ៧៥ ពូចូល កាលហ្នឹង ពូចូលធ្វើអីគេ?

ភឹមៈ ខ្ញុំទៅចម្ការកៅស៊ូ ចម្ការកៅស៊ូ ជាកៅស៊ូនៅស្នួលនេះណា ។ បាទ! ជាកៅស៊ូនៅស្នួលនេះ ដល់មក៧៧ ដល់មក៧៧,៧៨,៧៩ គេរើសចូលទាហានធ្វើបណ្ដោយ ។ វាយគ្នានៅ (ស្ដាប់ពុំបាន) ។ វាយគ្នាក្រុម(ស្ដាប់ពុំបាន) ។

បូលីៈ ព្រំដែនខ្មែរវៀតណាម យ៉ាងម៉េច?

ភឹមៈ នៅកៅស៊ូនៅឡើយទេណា ។

បូលីៈ នៅក្នុងស្នួលនេះទេ?

ភឹមៈ បាទ! នៅក្នុងស្នួល ។

បូលីៈ ពេលដែលពូធ្វើចម្ការកៅស៊ូហ្នឹង ជាស៊ីវិលទេ មិនទាន់ជាទាហានទេ ។

ភឹមៈ នៅស៊ីវិល!

បូលីៈ នៅក្នុងនាមជាអី? នៅក្នុងចម្ការកៅស៊ូ ឬជាអី?

ភឹមៈ ចម្ការកៅស៊ូ ។

បូលីៈ ប៉ុន្មាននាក់កាលហ្នឹង?

ភីមៈ និយាយរឿងច្រើនណាស់ណ៎ នៅក្នុងសហជីពនោះ សហជីពគេ ដឹងកាលហ្នឹង នៅក្នុងសហជីព ។

បូលីៈ បាទ!

ភីមៈ សហជីពហ្នឹង មិនដឹងប៉ុន្មាននាក់ទេ ។ ខ្ញុំអត់សូវដឹងដែរ ប៉ុនដឹងថាសហជីព កាលនោះគេដាក់ប្រុសៗផ្សេងណា គេអត់លាយលំគ្នាទេ លើកលែងតែអ្នកដាំបាយទេ មាននារីៗខ្លះនៅដាំបាយហ្នឹង ។ មានដាំបាយហើយ មួយសហជីពហ្នឹងសុទ្ធតែស្រីៗ បើនៅជាមួយ(ស្តាប់ពុំបាន) សុទ្ធតែជាមួយស្រីៗ បាទ! វាមានមួយដែរ អត់ទេមាន មានមេៗគេអីនោះឯងមាន បើថាកន្លែងគេមិនដាក់ចម្រុះទេ គេដាក់រៀងខ្លួនទាំងអស់ កាលហ្នឹងសូម្បីតែកូនខ្ញុំ គេឲ្យទៅកាប់ព្រៃ កៅស៊ូ គេមិនឲ្យជួបផងកាលហ្នឹង ។ គេអត់ជួបទេណា!

បូលីៈ ពីណាគេប្រធានសហជីពកាលហ្នឹង?

ភីមៈ ប្រធានសហជីព តាអីគេ ខ្ញុំអត់ស្គាល់ច្បាស់នេះទេ! តាពង្ស ។

បូលីៈ តាពង្សមួយ តារ៉ាន់ ។

ភីមៈ តារ៉ាន់?

បូលីៈ បាទ!

ភីមៈ តារ៉ាន់ហ្នឹងឯង និយាយវាវែងឆ្ងាយណាស់ តារ៉ាន់ អ្នកកាត់ទោស អ្នកទោសណា ។ អ្នកទោស ខ្ញុំឃើញផ្ទាល់ហើយអាដែងគេវាចោលណា ខ្ញុំឃើញ អ្នកដូចថាណៅសម័យនោះ អត់បាយហូបណា ។ ហូបបាយចឹងទៅ ប្រុចទៅទៀត រត់ទៅទៀត ហើយថាមិនស្គាល់គេមិនបញ្ជូនមកវិញ តាមខ្សែរយៈមកវិញ ដូចថាបញ្ជូនទៅត្រពាំងប្រាសាទទៅមួយថ្នាក់ទៅខាងត្រពាំងប្រាសាទ គេបញ្ជូនទៅតៗគ្នាដល់កន្លែង ។ ដល់កន្លែងយូរដែរណាបានគេវាយកាលនោះគេហៅទៅ ហៅទៅមួយសារទៀតគ្នាវាប់រយណ៎ ។ នៅពេញព្រៃកៅស៊ូ ចុះព្រៃកៅស៊ូមានញាតិណាវា ស្រលះជ្រិញ បានអង្គុយតាមព្រៃកៅស៊ូ គ្រែមួយនោះមួយ ធំដែរ! កន្លែងគេ ដាក់២នាក់ គេចងចុះទៅភ្ជាប់គេនៅក្រោយ ។ ឯណា១ថ្ងៃហូបបាយប៉ុននេះ ទម្រាំតែគេយកទៅវាយចោលណា បានខ្ញុំឃើញផ្ទាល់ បារាំងៗមេគេ(ស្តាប់ពុំបាន) គេកាត់ទោសអីហើយ គេនិយាយអីហើយចេះៗទៅ ចូលយើងធ្វើម៉េចធ្វើទៅៗ ។ (ស្តាប់ពុំបាន) អាខ្លះណា (ស្តាប់ពុំបាន) ចូលគ្នាទៅណា ។ ទៅមួយប្រោសណា ងាប់ណា ។

បូលីៈ វាយម្នាក់មួយដៃ ។

ភីមៈ អាខ្លះទៅបីដើង អាខ្លះបីកៅស៊ូ អាខ្លះដាល់ ថាធ្វើយ៉ាងម៉េចឲ្យបានរួមដៃគេ(ស្តាប់ពុំបាន) ។

បូលី៖ អ្នកដែលទៅវាយហ្នឹង មានចិត្តចង់ទៅវាយ ឬក៏គ្រាន់តែធ្វើឲ្យគេឃើញទេ?

ភីម៖ ដឹងឲ្យឃើញ ឬចិត្តចង់ចឹងឯង ខ្ញុំមិនសូវដឹងដែរហ្នឹង ទៅដល់បងប្អូនមក មិត្តយើងមកវិញ មកអន្ទុយវិញ(ស្តាប់ពុំបាន) ចូលរណ្តៅ រណ្តៅកាប់បាប់ហើយ(ស្តាប់ពុំបាន) ២នាក់ ។

បូលី៖ ឃើញហ្នឹងភ្នែកតែម្តងពូ?

ភីម៖ បាទ! អាហ្នឹងឃើញហ្នឹងភ្នែកហើយ ។

បូលី៖ ខុសអី? គេថាខុសអីកាលហ្នឹង?

ភីម៖ មានខុសអី! គេថាយើងរត់មកផ្ទះ ។ (ស្តាប់ពុំបាន) តាមសហករណ៍ គេបញ្ជូនមករហូតទៅដល់កន្លែង ដល់កន្លែងនោះគេចងបាត់ ។ កាលនោះមាននរណាគេតស៊ូ មានបេះតស៊ូអីកាលហ្នឹងនោះ ។ ទើបមកបច្ចុប្បន្នអីនេះទេ ទើបបេះតស៊ូនោះ ។

បូលី៖ ឈ្មោះអីដែលគេវាយពីរនាក់ហ្នឹង?

ភីម៖ នៅខាងសម្បូណ៌ ។

បូលី៖ មកពីសម្បូណ៌? .

ភីម៖ បាទ! សម្បូណ៌ខាងក្រចេះនោះ ។ នៅខាងហ្នឹងហើយ ប៉ុន្តែមិនដឹងខាងណាៗទេ គ្រាន់តែដឹងថាក្រចេះ ។

បូលី៖ ចឹងបានន័យថា សហជីពចម្ការកៅស៊ូហ្នឹងមិនមែនតែអ្នកស្លូលទេ?

ភីម៖ ចម្រុះទាំងអស់ ។

បូលី៖ ទូទាំងខេត្ត?

ភីម៖ បាទ! ទាំងអស់គេរើសទូទាំងភូមិ ។ ដូចថា១ភូមិ មួយក្រុមៗ! គ្រប់កន្លែងទាំងអស់ បាទ! ទាំងស្រីទាំងប្រុស ដាក់ចម្រុះទាំង អស់គ្នាតែម្តង ។

បូលី៖ មកហ្នឹង មកដាកៅស៊ូ ឬក៏ដាំកៅស៊ូ?

ភីម៖ អត់ដាំផង ដា!

បូលី៖ ដាវិញ?

ភីម៖ បាទ!

បូលី៖ បានច្រើនទេពូ កៅស៊ូ?

ភីម៖ កៅស៊ូកាលនោះ ដាកៅស៊ូចាស់ណាស់ កៅស៊ូជិនាន់បារាំងមុននោះ ។ កំប៉ោង កំបោះបេះតែក្បាលខ្វះតាមហ្នឹងទៅ ។ កៅស៊ូចាស់នោះ ខ្ញុំដាបានមួយឆ្នាំ បានគេផ្លាស់ទៅនៅដើរគ្នូបាន(ស្តាប់ពុំបាន) បានមកជួបក្មេងៗប៉ុនៗនេះ បានស្រួលជាបន្តិច ។

បូលីៈ ផ្លាស់ទៅណា?

ភីមៈ ទៅដើរគួរ ។

បូលីៈ ដើរគួនៅឯស្រែដែរទេ?

ភីមៈ បាទ! ប៉ុននៅ អាផ្លូវទៅយាកណាមយើងណា ។

បូលីៈ ផ្លូវទៅវៀតណាម?

ភីមៈ បាទ! ផ្លូវទៅចេះទៅនោះ ។

បូលីៈ បាទ!

ភីមៈ អាកន្លែងដើមគគីធំនោះ តាមនោះឯង ដល់ចេះទៅ ។

បូលីៈ ទីរួមស្រុករាល់ថ្ងៃ?

ភីមៈ បាទ! ដល់ចេះទៅ ។

បូលីៈ សហគម ដើរគួរហ៎?

ភីមៈ បាទ!

បូលីៈ ទីរួមស្រុករាល់ថ្ងៃ! គេធ្វើស្តូប២ធ្នូ ។ ឥលូវគេធ្វើស្តូបធំៗសិនអី ។

ភីមៈ ខ្ញុំនៅហ្នឹងតា ។

បូលីៈ នៅធ្វើអីនៅហ្នឹង?

ភីមៈ នៅដើរគួរ ។

បូលីៈ នៅធ្វើអីដើរគួ?

ភីមៈ នៅជាកៅស៊ូនៅឯង ។

បូលីៈ នៅជាកៅស៊ូនោះឯង ។

ភីមៈ គេផ្លាស់ពីគេហៅសម្រិបនោះៗ អាកន្លែងគេអាឈើនោះ ផ្លាស់ទៅ ទៅជា(ស្តាប់ពុំបាន) ។ គេរើស រើសគ្នា១ក្រុម រើសគ្នា១ក្រុមហ្នឹង មុនគេរើស គេដឹងមុនទៅហើយណ៎ា ។ ឲ្យសម្រេចតែប៉ុណ្ណឹង ទី១ជាកៅស៊ូ (ស្តាប់ពុំបាន) ។ បើនរណាគេជាស្អាត គេទៅជា(ស្តាប់ពុំបាន) ដល់តែរើសទៅប៉ះខ្ញុំដែរ ។ ខ្ញុំបានទៅជានោះវាស្រួលបន្តិច(ស្តាប់ពុំបាន) ប៉ុនៗមេដៃនោះ ចាស់បេះនោះតាមនោះ ។ មួយណាទៅអាតូចវាតូចនោះ បាក់ធ្លាក់គន្លាក់ក្រលុកថែម បើវាចាស់ហើយ(ស្តាប់ពុំបាន) ។

បូលីៈ ចាស់ហើយ?

ភីមៈ ចាស់ហើយ ។ បានមកដល់ថាយួនបុកហើយនោះ វាជីសទាហានបណ្តោយ រើសទាហាន ប៉ុនកាលពីមុនមក ខ្ញុំទៅដល់ទួលគ្រោះនោះ ។

បូលីៈ ទួលគ្រួសនៅឯណាវិញ ទួលគ្រួស?

ភីមៈ ហួសជើងភ្នំទៀត ។

បូលីៈ ក្បែរព្រំដែនទេ?

ភីមៈ ជិតព្រំដែននោះ ប៉ុនអត់ដល់ត្រពាំងស្រែទេណា បើនៅត្រពាំងស្រែអាហ្នឹង គេធ្វើស្រែ អានោះប្រពន្ធកងទ័ពណា យើងហៅត្រពាំងស្រែនោះឯង ។ ប្រពន្ធខ្ញុំនៅឯនោះទេ នៅជប់ម្ជូ ទេ ។ ហើយហួសពីជើងភ្នំ ទៅទួលគ្រួស អានោះដំបូងដូចយើងកាលយើងបុកដំបូងណា ។ គេឲ្យទៅជញ្ជូនបាយ បានតែ១ជើងហ្នឹង មានបានមកវិញណា ។ កាត់អាផ្លូវព្រៃណាណី ផ្តសផ្តាស់ ធ្លាក់ភូមិដូងមិលនេះ មកដល់មើលភូមិដូងឯនេះ ។

បូលីៈ ចឹងពូនៅហ្នឹងតែជាកៅស៊ូទេណ៎?

ភីមៈ បាទ! នៅហ្នឹងជាកៅស៊ូ ។ គេហៅមានកងវរគេអីទេ?

បូលីៈ អត់ទេ! កាលហ្នឹង គេមានហៅសហជីពចឹង?

ភីមៈ បាទ! ប៉ុន្តែសហជីពផ្សេងខ្ញុំអត់សូវស្គាល់ណា ។ ខ្ញុំស្គាល់សហជីពសម្រិប គេហៅសហជីប សម្រិបៗមួយ អាកន្លែងមកពីថ្ពង់មួយនោះ មកពីថ្ពង់មួយមានអាទួលនោះ គេហៅសម្រិប ព្រៃសម្រិបគេហ្នឹង ។

បូលីៈ សហជីពព្រៃសម្រិប?

ភីមៈ បាទ! ទៅនោះមានជើងភ្នំ ។

បូលីៈ អាហ្នឹង សហជីពមួយទៀត ។

ភីមៈ ទៅណាខ្លះទេ ខាងរហាលខាងក្របីចូលរូងណាណី ខ្ញុំដើរទៅមិនអស់ទេកាលហ្នឹង ដើរឯណា ម៉ោង៨ចាប់ផ្តើមវាយដួង ។ តម្រង់ផ្លូវវាកើត មិនកើត កាត់អេ៎ ។

បូលីៈ តាំងពីព្រលឹមតែម្តងចឹង?

ភីមៈ បាទ! ម៉ោង៨ហើយ ឥលូវក្រុមណា គាត់អីឈឺពោះ ឈឺអីប្រាប់គេ ប៉ុន្មានៗអ្នក ក្រុម នោះឯង ទៅសាងលេខគេ ។

បូលីៈ សាងលេខយ៉ាងម៉េច?

ភីមៈ សាងលេខដូចថា ដើមកៅស៊ូហ្នឹង ដូចថាប៉ុន្មាន៥ជួរហ្នឹង ជាអស់ហើយ មកជួយអាកៅស៊ូ នេះ! មករួមគ្នាទាំងអស់អាកៅស៊ូជួយអ្នកគ្រុនអ្នកអីឈឺពោះ ឈឺអីមិនបានទៅណា ។ មក

ជួយទាំងអស់គ្នា ដល់ហើយដាហើយអីហើយបានទៅសារបស់ខ្លួនឯង។ បានទៅសារបស់ខ្លួនឯងហើយ បានទៅសារបស់រួមទៀត ចឹងបានទេដុះទៅសម្បែង ប៉ុនខ្ញុំ(ស្តាប់ពុំបាន)វាម្យ៉ាងត្រង់ថា បាយហូប(ស្តាប់ពុំបាន)ជាមួយគាត់មែនណា ប៉ុនគាត់ថាមិនមែនម្ហូប បេះផ្លែឈើតាមព្រៃ(ស្តាប់ពុំបាន) បាទ! ឃើញថាផ្លែសម្រាង ផ្លែប្រម៉ាត់ចឹងទៅយកទៅណាមិនអស់ទេហូបចុះហើយហ្នឹងក្រូច អាក្រូច(ស្តាប់ពុំបាន)នេះ។ ក្រូចដុង គំពស់ៗនេះ!

បូលីៈ យើងបេះហូបបានដែរ គេអត់ចាប់ចងអីទេ?

ភីមៈ អត់ទេ! បើថាដំណាំរបស់យើងដាំ អានោះអត់បានទេ។ តែបើគេថាគេនិយាយហា៎ បោះខ្ញុំហូបទៅ ខ្នុរកំពស់ៗនេះហូបទៅ។ ប៉ុន្តែ ខ្ញុំអត់ហូបផ្លែ(ស្តាប់ពុំបាន) ផ្កាក់មកប៉ុនៗនេះ។ (ស្តាប់ពុំបាន ) ខ្នុរអី បេកអីតាមព្រៃតាផ្សែនោះបេះនោះ!

បូលីៈ ពូស្គាល់គណៈស្រុកស្នួលទេ?

ភីមៈ ទេ! អត់ស្គាល់ទេបង។

បូលីៈ ហើយពេលដែលផ្ញើសហជីពហ្នឹងមាន អ្នកធំៗគេចុះមកមើលទេកាលហ្នឹង?

ភីមៈ បាទ! អត់មានអីទេ មានតែ តាពង្ស និងតាវ៉ាន់ហ្នឹង ឯងមេគេនោះ!

បូលីៈ តែ២ហ្នឹងទេ?

ភីមៈ បាទ! តែ២នោះ។ ប៉ុន្តែគេណាត់ ជួបនៅកន្លែងគេណាត់ ហានចូលអី មិនហានចូលទេ។ អត់មានថ្នាក់មកពីភ្នំពេញៗមកមើលទេ?

បូលីៈ អត់មានអ្នកធំ ចុះមកមើលកៅស៊ូ មើលអីទេ?

ភីមៈ អត់មានទេ! ព្រោះមិនដែលដឹង យើងអត់ថានោះណា ព្រោះខ្ញុំដឹង មកទីណាទីណី ខ្ញុំអត់ដឹងដែរ បើថាខ្ញុំដឹង ខ្ញុំអត់មានដឹងទេ អត់មានខេត្តអីណាស្រុកណា មកទៅទេ។

បូលីៈ ចុះពូដែលឃើញ ចិនអីទេ អ្នកជំនាញការចិនអី?

ភីមៈ អត់មានទេ!

បូលីៈ តែខ្មែរយើងសុទ្ធតែម្តង?

ភីមៈ បាទ! គ្មានចិនទេ។

បូលីៈ ដល់ពេលប្រមូលជ័របានយកទៅណាទៅ?

ភីមៈ ទេ! ខ្ញុំមិនដឹងដែរ ដឹកឡានយកទៅ។ បាទ! ដល់ពេលគេដឹកមកទៅ ជួនណាខ្ញុំទៅបង្ហាញជ័រគេជិះឡានជាមួយគេទៅ ចូលតាមផ្លូវកៅស៊ូទៅ។ ប៉ុន្តែទៅបង្ហាញអី ខ្ញុំជួយលើកដែរហ្នឹង។ ជ័រស្អុយជម្រុកហ្នឹង អាជ័រនៅលើកចេញពីឡាំងវានោះ ឡាំងឈើនោះ។ គាស់ពីដីផងអីផង

មិនមែនទៅសួតឯណា ផ្ទាក់ប្រើកបោះចុះ បោះឡើងរន្ទាក់រន្ទិល ប្រលាក់ស្អីពេញមុខហ្នឹង ដង្កូវ ចង់ប៉ិនកូនដៃៗ ដុះរោម ដុះកន្ទុយ អាដង្កូវនោះណា។ អាដង្កូវកៅស៊ូនោះ ធំៗណាស់ អាដង្កូវកៅស៊ូនោះ ប៉ុនៗចង្កឹះអាដុះកន្ទុយ។ ដូនគេដើរដួនឡើងឡានពេញឡានអស់ហើយ អស់ហើយបានខ្ញុំដើរចូលទៅឡានវិញទៅ មិនដឹងគេយកទៅណាទេ មិនដឹងដែរបាទ! ខ្ញុំអត់ដឹងអីទេ។

បូលី: ហើយឆ្នាំ៧៧ បានពូចូលកងទ័ព?

ភីម: ៧៥។

បូលី: ៧៥ ក្រែងជាកៅស៊ូសិនអី?

ភីម: បាទ! ៧៥ជាកៅស៊ូបាន ៧៩ បានចូលទ័ព។

បូលី: ចូលហ្នឹងយើងចង់ចូល ឬក៏គេឲ្យចូលទ័ព?

ភីម: ណាទៅចង់ឯណា គ្រាប់! ប៉ុនថាបើគេឲ្យទៅហើយ មិនទៅយ៉ាងម៉េច សម័យនោះហើយ។ មិនថាពីណាពីណាទេ បើយើងមិនទៅមិនដឹងជាធ្វើយ៉ាងម៉េច។ បាទ! មើលមិនឃើញដែរ បើយើងថាទៅហើយទៅធ្វើយ៉ាង។

បូលី: កាលហ្នឹងនៅក្នុងសហជីពពូហ្នឹង ពូធ្វើយ៉ាងម៉េច មានតែពូទេ ឬក៏មានមិត្តភក្តិនរណាផ្សេង?

ភីម: មាន! រើសជាក្រុមតែម្តង។ ជាក្រុមបងប្អូន ប្អូនជីដូនមួយខ្ញុំមួយ ខ្ញុំស្គាល់ណា ក្រៅពីនោះមិនស្គាល់ទេ ខ្ញុំភ្លេចអស់ហើយ! ប៉ុន្តែបងប្អូនជីដូនមួយខ្ញុំនោះ នៅរហូតទាល់តែសព្វថ្ងៃ តែគេទៅផ្ទះអស់ហើយ គេទៅតាំងពី អាវាយផ្តាច់ វៀតណាមនោះ គេរត់ទៅផ្ទះបាត់អស់ហើយ។ ខ្ញុំនេះរត់ទៅរត់ទៅរហូតទៅ!

បូលី: ពេលដែលពូចូលទៅ ពូចូលទៅក្នុងកងពលលេខប៉ុន្មានកាលហ្នឹង?

ភីម: កាលខ្ញុំ កាលដែលខ្ញុំនៅទន្លេ ខ្ញុំអត់មានលេខឯណាទេ កាលនោះណា! កាលហ្នឹងដូចថាទៅតាពីតាពាសម៉េចនោះទេ ហូបដំឡូង ហូប(ស្តាប់ពុំបាន) ក្តួចហើយដំឡូងនោះ។ ទៅ៨១ បានខ្ញុំឡើងទៅ១០០១ ឡើងទៅដីលាវចូល១០០១។

បូលី: ប៉ុនពេលដែលវាយជាមួយយួនហ្នឹង នៅក្នុងកងអីគេហ្នឹង?

ភីម: អាហ្នឹងអត់ទាន់ឡើងភ្នំទេណា!

បូលី: ហ៊ូ! អត់ទាន់ឡើងទេណាពេលវាយជាមួយយួននៅស្នួលណា ព្រំដែន?

ភីម: កាលនៅជាមួយអាដែង មេឈ្មោះតាគឿនៗ មេគេនៅហ្នឹង។ កងពលវរៈ៩!

បូលី: វរៈធំ ឬក៏វរៈតូច?

ភីម: វរៈតូចណា ទេ! វរសេនាធំគេទេដឹង ។ ខ្ញុំអត់សូវច្បាស់ទេកាលហ្នឹង ។

បូលី: អត់ចាំលេខកងពលទេណ៎?

ភីម: បាទ!

បូលី: ដែលពូសួរ?

ភីម: ដឹងថាលេខ១៩! ហើយបើវរៈផ្ទះនៅមុខនេះ ផ្ទះខាងមុខនេះគេវរៈ២០ ។

បូលី: ពីណាគេ?

ភីម: តាភាយ!

បូលី: ហ៎ូ! ភាយ ។

ភីម: គេធ្វើទាហានណ៎ ឥលូវឡើងមេ ឡើងអីទៀតហើយ ។ អាភាយអីកើតហ្នឹង ខ្ញុំហៅភាយៗ រហូត(ស្ដាប់ពុំបាន) នៅខាងចុងយើងនេះ ។

បូលី: នៅវរៈ២០?

ភីម: បាទ! វរៈ២០ ។

បូលី: ពូ១៩?

ភីម: បាទ! ១៩ ។

បូលី: នៅនេះកងពល១៧ទេអី?

ភីម: ទេ! ខ្ញុំអត់ច្បាស់ទេកាលហ្នឹងនោះណា ។ ប៉ុនបើថានេះហើយនៅ១៩នេះឯង ។

បូលី: ពូស្គាល់តាហឿនទេ?

ភីម: តាហឿនណ៎!

បូលី: មេទ័ពធំនៅក្រចេះ?

ភីម: ទេ! អត់ស្គាល់ទេបង ។

បូលី: តាហឿននៅត្រពាំងប្រាសាទយើងនេះឥលូវ ក្រោយមកគាត់ធ្វើមេកងពល៦១២ ពេលមកលើភ្នំនោះ ។

ភីម: ខ្ញុំអត់ស្គាល់ដែរ! ខ្ញុំនៅជាមួយគាត់តាំងពីទន្លេ ទន្លេតូចណ៎!

បូលី: ក្រោយ៧៩ទៀត?

ភីម: បាទ! និយាយរួមទើបបែកជាមួយគាត់ពេលគាត់ផ្ដាច់ខ្លួននេះ ។

បូលី: ប៉ុនមុន៧៩ ពូអត់ដឹងថាពូនៅកងណាទេណ៎?

ភីម: បាទ! មុន៧៩ ខ្ញុំមិនដឹងនៅឯណាទេ ។ ទេ! ៧៩ ហ្នឹងខ្ញុំនៅចម្ការកៅស៊ូ ។

បូលី៖ ប៉ុន្តែពូចេញពីចម្ការកៅស៊ូ មកធ្វើជាកងទ័ពអត់ស្គាល់កងពលទេហ្នឹង?

ភីម៖ បាទ! នៅជាមួយគាហៀនហ្នឹងហេ៎ មិនដឹងកងពល វរសេនាធំ ឬវរសេនាតូចទេណា ។ បាទ! ប៉ុនគេនៅជួបជុំជាមួយគាហៀនៗហ្នឹងឯង កាលនោះ មិនដឹងថាគាត់ទៅនៅឯណា មិនដឹងស្លាប់ ឬក៏រស់ទេ កងពលណាណីទេ ។

បូលី៖ បើនៅក្រចេះ មានពីរកងពល! មានកងពល១១០ ហើយកងពល១៨០ ។ ដែលឮឈ្មោះកងពលនេះទេ?

ភីម៖ ឮ! តែខ្ញុំវាមិនច្បាស់ដែរ ។

បូលី៖ វាអាចវរៈរបស់ពូហ្នឹង វាអាចនៅក្នុងកងពល មួយក្នុងចំនោមកងពល២ហ្នឹង ។

ភីម៖ អាហ្នឹងចឹង ប៉ុនមិនដឹងជានៅជាមួយពីណា ។ បាទ! គ្រាន់តែវាមិនចាប់អារម្មណ៍ណា ទៅណាក៏ចេះតែទៅហ្នឹងគេទៅ បាទ!ថាចឹង ខ្ញុំមិនចាប់អារម្មណ៍ទេ ។

បូលី៖ ហើយដែលវាយហ្នឹង វាយជាមួយយួន ទម្រាំយើងវាយបាក់ទ័ពមក?

ភីម៖ បាទ! និយាយរួម អានៅដែលស្រួលណា ។ នៅមួយវស្សា! វាយដល់មកសម្រុកពីវស្សាមកអត់រួចទេណា ។ រហូតទល់ប្រាំង ខែច្រូតស្រូវនោះឯង បាទ! ប៉ុនមិនដឹងនៅខែអីទេណា ខែរាំងអស់ហើយណា រាំងស្ងួតអស់ហើយនោះ វាយបុកមកបណ្ដោយ ។

បូលី៖ យួនហេ៎?

ភីម៖ បាទ! បើខែវស្សាទោះបីម៉េចក៏មកមិនរួច កាត់ ភក់ ទឹកណា ដល់នេះខែប្រាំង ខែប្រាំងបានបុកមកបន្តទៀត ។ បុកមកវិប ខ្ញុំអស់ហើយ តាំងពីស្នួលមក ។ យកនេះឲ្យ ដល់មកហ្នឹង ចេញពីកៅស៊ូ មកដាំបាយតែម្ដង ។ ដាំបាយ! តែមានបាយណាហូប បើចេះតែបាក់ទៅៗ ហើយបាយចេះទៅដែរ ចេះទៅបន្ថែមទៅ ។ ដល់រហូត មកដល់ឆ្លងមកក្រចេះទៅខាងសម្បូរកោះឆ្លងទូកអីទៅណា ។ មានជិះទូកគេណា បើទឹកទន្លេ អត់ចេះហែលផង ។ ហែលបានតែអូរតូចៗចេះ ដល់ទន្លេល្វឹងល្វើយទៅហែលម៉េចកើត តោងក្បាលទូកគេណាដល់ត្រើយ ។

បូលី៖ ឆ្លងទន្លេមេគង្គ?

ភីម៖ បាទ!

បូលី៖ ឆ្លងទៅមុំណា មុំសម្បូរ?

ភីម៖ ឆ្លងខាងលើសម្បូរទៀត ។

បូលី៖ លើសម្បូរទៀត?

ភីមៈ បាទ! ឆ្លងកោះរង៉ាវនោះៗ

បូលីៈ មុំកោះរង៉ាវនោះ?

ភីមៈ បាទ! កោះរង៉ាវ ធ្លាក់ ខ្ញុំឆ្លងមកខាងអូរយ៉ាវៗ

បូលីៈ អូរមកខាងយ៉ាវហ៎?

ភីមៈ បាទ! ទៅយ៉ាវ ហើយបានមកខាងភ្នំដីវិញៗ ភូមិដី ហើយបានមកភ្នំក្តីហើយ ភ្នំក្តីមកយួននៅហ្នឹងបណ្តោយៗ យើងរត់ចូលផ្ទះប្រជាជននោះ ហើយផ្លូវបន្ទាប់ៗណា ប្រក់ស្បូវប្រក់អី បន្ទប់ៗៗ គ្នាខ្ញុំ គ្នា៩នាក់ ប៉ុនកាំភ្លើង ខ្ញុំកប់ចោលអស់ហើយអត់ទុកទេៗ ខ្ញុំស្លៀកក្រមាទេ ប៉ុន្តែអាវទាហាននៅ ខោៗទាហានដែរ ប៉ុន្តែស្លៀកក្រមាពីលើ ខោណ៎ៗ ពូនៗឲ្យគេទៅបាត់ រថក្រោះមួយ ឡានប៉ុនរថក្រោះមួយ ដឹងថារថក្រោះមួយ ប៉ុនមិនដឹងថាឡានប៉ុន្មានទេនៅខាងមុខ រថក្រោះនៅតាមក្រោយ! ខ្ញុំលួចមើលចេះហ្នឹងណា មិនឆ្ងាយណា ជិតប្រហែលជាជុំរុំនោះឯង អាតាមអាដែងគេ ឫស្សីបណ្តឹះៗ ប្រហោងនោះ ងើយមើលទៅ ដល់វាទៅផុតទៅ សួរកប៉ុល ពតដែលណាៗ ប្រជាជនលាក់ដែរណា! មិនឃើញទេ មិនដឹងឯណាទេ ប៉ុល ពតៗ អត់ដឹងដែរ ខ្ញុំអ្នកជម្លៀសដែរនោះ ភូមិនោះរត់ទៅឯនោះៗ ដល់យើងមកនេះមក (ស្តាប់ពុំបាន) ទៅផ្ទះវិញទៅណាៗ វាពទ្ធ័មកចេះវិញទៅណាៗ ហើយខ្ញុំ បើគេព័ទ្ធហើយ ក៏ត្រលប់មកវិញដែរ ខ្ញុំទៅនៅខាងអូរយ៉ាវ ទៅនៅអូរយ៉ាវហើយ ដល់ទៅគេ ប្រាប់ថាទៅនៅជ័យភណ្ឌ ភូមិជនជាតិ ខាង១០៥នោះៗ

បូលីៈ ១០៥ នៅមណ្ឌលគិរីវិញហ្នឹង?

ភីមៈ ទេ! អត់ដល់ទេៗ តាមវេញទ្បើពីលើ តាម(ស្តាប់ពុំបាន) នៅលើអីយើងហ្នឹងៗ ដល់ទៅមានទៅយកស្លឹនៅលើហ្នឹង ក៏នៅហ្នឹងបណ្តោយរហូតៗ

បូលីៈ អាហ្នឹងភូមិសាស្រ្តស្រុកអីគេ អាហ្នឹង?

ភីមៈ អាហ្នឹង មិនដឹងជាហៅអី អាហ្នឹង នៅស្រុកហ្នឹងរហូតដែរៗ

បូលីៈ នៅស៊ឹងត្រែង?

ភីមៈ ទៅពីភូមិផ្លៀយើងទៅនោះ ខាងចន្ទុល ខាងភូមិថ្មី វាចេះណា តាមមាត់ព្រៃ ទៅលើចេះទៅៗ

បូលីៈ (ស្តាប់ពុំបាន) ៗ

ភីមៈ ជិតផ្លូវៗ

បូលីៈ ខាងចន្ទុល អូរក្រាវ អូរព្រះអីទេអី?

ភីមៈ បាទ! ខាងនោះឯង គ្រាន់តែ(ស្តាប់ពុំបាន) មួយជំនាន់នោះ។

បូលីៈ ហើយនៅហ្នឹងទៅ?

ភីមៈ បាទ! ទៅខាងនោះ ភ្នំខ្ពស់អីនោះ។ ហូបក្តួច ហូបដំឡូង! ក្តួចត្រាំទឹក ដល់ពេលអស់អាក្តួចហ្នឹងទៅ ចឹងអស់ទៅថ្នាំដូចទឹកចឹង យកអាម្សៅ ព្រោះយកយកគោកហូបទៀត ហើយអត់អំបិលទៀត។ ដាច់មួង១ដែរ អំបិលណា ប៉ុន្តែខ្ញុំវាមិនដាច់ខ្វះ មិនដាច់ទេណា ព្រោះនៅជិតភូមិណា។ បានពេលចូលភូមិបានទៅ ហើយម្តុំយើងអាដែង(ស្តាប់ពុំបាន) ពេលចាប់ដៃចាប់ដៃដាប់ ឧបមាថាថ្ងៃ១៩ ទៅថ្ងៃ២០ចឹងកំណត់ឲ្យចាប់ដៃ ចាប់ដៃទៅ។

បូលីៈ ឈ្លបខាងណា?

ភីមៈ ឈ្លបខាងហ្នឹងឯង។

បូលីៈ ខាងរដ្ឋាភិបាល?

ភីមៈ បាទ! ប៉ុន្តែត្រូវសជាមួយខ្ញុំណា។ យាម! បើថាស្ពានចឹង ឈ្លបយើងប៉ុណ្ណោះហើយខាងគេ យាមឆ្លងស្ពានខាងនោះ មកអត់ដល់គ្នាទេ។ គេថាមកដល់បាញ់ ខាងនោះគេបាញ់ពួកខ្ញុំ នៅកណ្តាលនោះ ជាមួយប្រជាជនជាមួយឈ្លប។

បូលីៈ ប៉ុន្តែ កាលរស់នៅ យប់ព្រលប់ពីពូទៅរស់នៅ ក្នុងភូមិ ឬក៏នៅក្នុងព្រៃ?

ភីមៈ ក្នុងព្រៃជាប់២ឆ្នាំ ទៅ៣ឆ្នាំនៅព្រៃជាប់។

បូលីៈ ព្រៃរហូត?

ភីមៈ បាទ! មានភូមិណាសម្រាកអត់ទេ។

បូលីៈ ពេលដែលរត់បាត់ វាយពីវៀតណាមវាយមក ពូឡើងមកលើភ្នំសិន បានចុះមកវិញ ឬក៏នៅក្នុងព្រៃហ្នឹងរហូត?

ភីមៈ នៅក្នុងព្រៃរហូត។

បូលីៈ អត់មានឡើងមកភូមិសោះ?

ភីមៈ អត់ទេ! មករហូត។ ក្តួច ដំឡូងនៅតាមមាត់ទន្លេ ហូបមួយចប់ និយាយរួមស្អីក៏ហូបដែរកុំឲ្យតែពុល។

បូលីៈ ប៉ុន្មាននាក់ក្រុមលោកពូ?

ភីមៈ មួយក្រុមខ្ញុំ?

បូលីៈ បាទ!

ភីមៈ ក្រុមខ្ញុំ អានៅផ្ទះនេះមួយ! នៅជាំប្រាសាទនេះមួយ(ស្តាប់ពុំបាន) ហើយក្រៅពីនោះគេនៅក្រៅនោះ ទៅប៉ះនៅម៉ុំអូរគ្រាវនោះ ទៅអូរគ្រាវនៅម៉ុំស្រុកនោះមួយសារនោះ ។ ខ្ញុំនៅភ្នំពេញនោះទេ រាប់ផ្ទះនេះមួយៗ នៅត្រពាំងប្រាសាទនេះមួយ ។

បូលីៈ កាលពីពេលដែលនៅក្នុងព្រៃនោះ ប៉ុន្មាននាក់ទៅអ៊ី?

ភីមៈ អ្នកនៅភូមិខ្ញុំ?

បូលីៈ បាទ!

ភីមៈ ច្រើនណា! ប្រហែលជាប់ជា២០នាក់នោះ ។

បូលីៈ ២០នាក់?

ភីមៈ បាទ!

បូលីៈ ២០នាក់! ប្រុសសុទ្ធ ឬក៏ស្រីដែរ?

ភីមៈ សុទ្ធតែប្រុសៗ ។

បូលីៈ ទាហានសុទ្ធតែម្តង អត់មានស្រីទេ?

ភីមៈ ទាហានសុទ្ធតែម្តង ។

បូលីៈ ចឹងពូការហើយនៅកាលហ្នឹង?

ភីមៈ អត់មានទេ!

បូលីៈ អត់មានទេណ៎?

ភីមៈ បាទ! ខ្ញុំទើបតែយកក-៧នេះតា ។

បូលីៈ ហ្ន៎! ទើបតែយកនៅក-៧នេះទេ?

ភីមៈ បាទ! ដណ្តឹងទាំងពី១០០១ ។

បូលីៈ ដណ្តឹងទាំងពី១០០១ ដល់មកការនៅក-៧?

ភីមៈ ខ្ញុំការនៅក-៧! ចុះខ្ញុំមានបាននៅផ្ទះឯណា ។ ទៅកំពង់ចាម កំពង់ធំ ស្វាយរៀង ។

បូលីៈ ពូនៅក្នុងព្រៃ នៅក្របេះហ្នឹង នៅប៉ុន្មានឆ្នាំបានឡើងមក១០០៣នេះ?

ភីមៈ និយាយទៅតាំងពី៧៩,៨១ ។

បូលីៈ កាល៧៩ រត់វៀតណាមវាយ យួនវាយឯណា?

ភីមៈ បាទ! យួនវាយឈ្នះ(ស្តាប់ពុំបាន) រត់ចូលព្រៃបាត់ ។ ដល់៨១ បានខ្ញុំឡើង ។

បូលីៈ ៨១ ខែប៉ុន្មាន?

ភីមៈ ខែ៨ ។

បូលី:	បើសាច់នៅក្នុងព្រៃ១ឆ្នាំ កន្លះចឹង?

ភីម:	បាទ! ក្តួច ដំឡូងៗហើយ ។

បូលី:	តែបើ១ឆ្នាំកន្លះហ្នឹងយើង ធ្វើអីទៅ?

ភីម:	អត់ទេ! អត់មានធ្វើអីទេ ដើរតែមួយរស់ៗតែម្តង ។

បូលី:	មួយរស់តែម្តងៗ?

ភីម:	បាទ! អត់មានទៅធ្វើការ ប្រជាជនអត់ទេ ។

បូលី:	ម៉េចបានយើងចូលជាមួយរដ្ឋាភិបាលតែម្តងទៅ?

ភីម:	(ស្តាប់ពុំបាន) គេឃោសនាចេះ ឃោសនាចុះណា បាទ! នយោបាយវៀនខ្ទួន មិនដឹងថា ម៉េច អាខ្លះ ចូលទៅវះពោះចេះ អាខ្លះវះពោះចុះ ដល់ចេះ បើគេឃោសនាចុះ ។ បើរត់ចោលទៅ មេមិនងាប់តែឯងនោះ ។ បាទ! ឃើញចឹងណា បើគេថាចឹងទៅ បើមិនទាំងមេ មិនទាំងកូន ។ ចេះតែខ្លាចទៅណា!

បូលី:	ពូថាឃោសនាយួនវះពោះ ញាត់អីស្មៅអីហ្នឹងណា?

ភីម:	បាទ!

បូលី:	ចេះតែខ្លាចៗទៅ?

ភីម:	មិនដឹងទីណាទីណី ណាខុសនរណាត្រូវ កាលហ្នឹងមិនដែលយល់ស្អី ។

បូលី:	បើសិនដឹងថាស្រួលចូលហើយណ៎?

ភីម:	ចុះស្រុកខ្ញុំដែរណា ទៅពីនេះដល់ហើយណ៎ ដីដែលខ្ញុំនៅណា មានខ្លាចអី កាត់ចេះទៅកើតទៅ! ធ្លាក់ទៅភ្នំព្រេចទៅ ភ្នំព្រេចនោះ ចូលស្វាយទាបប្លុកនោះឯង មានទីណាទីណីៗ នៅក្បែរនេះ ប៉ុន្តខ្ញុំអត់ទៅ គេថាចុះពីរ!

បូលី:	ចុះពូមានដែរ ទៅភ្នំ៥០០០នេះ?

ភីម:	អត់ដែលទៅទេខ្ញុំនោះ ខ្ញុំនៅខាងនោះ ភ្នំ៥០០០ នៅកងជ្វេងៗ

បូលី:	កងគេជ្វេង?

ភីម:	បាទ! ប៉ុន្តែ មិនកងនៅខាងណាទេ មិនដឹងដែរ នៅគ្រប់កន្លែងគេនៅ ។

បូលី:	ពេលដែលពូនៅក្នុងព្រៃ ១ឆ្នាំកន្លះហ្នឹងណា ពូទំនាក់ទំនងជាមួយមេធំតាមណា?

ភីម:	អត់ទេ! មិនដឹងតាមណាទេ មេខ្ញុំមិនសូវដឹងដែរ ។

បូលី:	មានគេអូ មានអីទេ?

ភីម:	ទេ! ដោយក្រោយមានៗ

បូលីៈ តែមុនពេលដែលរស់នៅហ្នឹងមានទេ?

ភីមៈ អត់ទេ!

បូលីៈ ចុះធ្វើម៉េចទាក់ទងគ្នា ដើម្បីយើងឡើងលើភ្នំបាន?

ភីមៈ យើងមានកម្លាំងចុះពីលើភ្នំទៅៗ ចុះពីលើភ្នំទៅសហការគ្នា! ដុះចុះទៅមានគេអូ មានអីស្រេចៗ ដល់មានគេអូ ដឹងអស់រលីង គេឲ្យចែកមេៗទៅៗ ដឹងឡើងម្តង ដឹងមកកម្លាំងវាចុះពីភ្នំទៅយក បាទ! មិនមែនកម្លាំងវាឡើងមកទេណា បាទ! អត់មករួចទេៗ ស្គាល់ភូមិសាស្ត្រ ដល់ចុះទៅ មួយក្រុមនោះទៅ ចុះទៅដល់កន្លែងភូមិហ្នឹង ១០ថ្ងៃកន្លះខែ គេ(ស្តាប់ពុំបាន)ៗ

បូលីៈ ដើររហូត?

ភីមៈ បាទ! ដើររហូតៗ

បូលីៈ ហើយដើរប៉ុន្មានខែបានដល់?

ភីមៈ ខ្ញុំដើរ មិនដឹងបានប៉ុន្មានដណ្តប់ថ្ងៃ!

បូលីៈ វៀងឆ្ងាយដែរៗ

ភីមៈ ប៉ុន្មានជា១ខែ ខ្ញុំមិនទេភ្លេចបាត់ហើយៗ ប្រហែលជាបាន១៨ ទៅ១៩ថ្ងៃហ្នឹងៗ

បូលីៈ ពូមកនៅក្រចេះ នៅមុំស្រុកសម្បូរស្នួលៗ នេះ(ស្តាប់ពុំបាន) នេះសម្បូរមុំនេះ ហើយពូនៅ ១០០១ នេះមុំពណាពូៗ ចឹងដើរឆ្លងតាមណា បើមុំនេះមាត់ទន្លេ?

ភីមៈ ខ្ញុំឆ្លងមកតាមទន្លេ ឆ្លងមកតាមកោះរងាវ បាទចេញមកតាមកោះរងាវមក មកចំមុខកប៉ាល់នេះៗ ហើយមកខាងដីលាវវិញ មកដីលាវៗ

បូលីៈ កាត់ខេត្តស្ទឹងត្រែងទេ?

ភីមៈ ក្រៀងៗ

បូលីៈ ខេត្តអីអាហ្នឹង?

ភីមៈ ក្រៀង! មិនដឹងជាខេត្តអីទេៗ ក្រៀងនៅមាត់ទន្លេណុ៎ៗ

បូលីៈ ក្រៀងមាត់ទន្លេ!

ភីមៈ អូរក្រៀងៗណាៗ

បូលីៈ ហ៊ូ៎! អូរក្រៀងៗ អូរក្រៀងក្រចេះតាៗ

ភីមៈ នៅក្រចេះ! (ស្តាប់ពុំបាន)ៗ

បូលីៈ ពីមុនដល់១០០១ ពូត្រូវឆ្លងស្ទឹងត្រែង ឆ្លងព្រះវិហារ?

ភីមៈ បាទ!

បូលីៈ ឆ្លងខេត្តស្ទឹងត្រែង?

ភីមៈ បាទ!

បូលីៈ ហើយបានមកជែប មកព្រះវិហារ ។

ភីមៈ បាទ! ព្រះវិហារ ។

បូលីៈ ហើយបានមក១០០១បាន?

ភីមៈ បាទ! ខាងផ្លូវជែបនោះណា បានព្រៃស្អី កាលនោះ! ផ្លូវស្អីទេ ផ្លូវកាលនោះដីលាវ កាលនោះព្រៃធំ ព្រៃដីរនោះ ។ ហើយតាមច្រាំងទឹកអីឃើញ អាចម៍ អាចម៍អីឲ្យគំរៀប នោះព្រោងព្រាត ។ បាទ! អត់ដឹងដែរ កាលនោះវាមិនដឹងខាងណា ខាងណីទេ ខេត្តណា ខេត្តណីទេ ។ ចេះតែកាត់ព្រៃផ្សេងគេជូននោះ ។

បូលីៈ មានអ្នកនាំផ្លូវដែរ?

ភីមៈ បាទ! នាំមកនោះ ខ្ញុំមិនដឹងដែរនោះ ។

បូលីៈ ពេលឡើងមកដល់១០០១ហ្នឹង ពូសម្រាកបានប៉ុន្មានខែ បានពូចុះទៅវិញ?

ភីមៈ យូរដែរ! សម្រាកបាន២ ទៅ៣ខែដែរណា ។

បូលីៈ ពូមកដល់បានខែ៤ ឆ្នាំ៨១ មិនចឹង?

ភីមៈ បាទ!

បូលីៈ ឡើងមកដល់ មានគេរៀបចំនៅ?

ភីមៈ កាលហ្នឹង កាលខ្ញុំឡើងមកគេមិនទាន់រៀបទេ ដល់ក្រោយមកដូចថាបាត់ហត់បាត់អីណាស្រួលបួលហើយ បានគេរៀបចំកងពលទៅ បានដឹងកងដឹងអីទេ បានគេប៉ុន្មានខែទេ បានគេឲ្យសម្រាកទៅណា! បាទ! យូរដែរ ។ រឿងខែ ខ្ញុំអត់ដឹងច្បាស់ទេណា រឿងខែ គេឲ្យណា ។

បូលីៈ គេបញ្ចូលពូទៅក្នុងកងលេខ កងពលណា កាលហ្នឹង?

ភីមៈ ៨០១ ។

បូលីៈ ៨០១?

ភីមៈ បាទ! ៨០១ ។

បូលីៈ ជាមួយតាសារឿន?

ភីមៈ បាទ! តាសារឿន តា០៥ ។

បូលីៈ នៅក្នុងវរៈលេខប៉ុន្មានកាលហ្នឹង វរសេនាធំលេខប៉ុន្មាន?

ភីមៈ ទេ! មិនដឹងជាលេខប៉ុន្មានទេ វរសេនាធំ ។

ប៊ូលីៈ ៨០១?

ភីមៈ បាទ! វរសេនាធំលេខប៉ុន្មានទេ ខ្ញុំភ្លេចបាត់ហើយ ។ ប៉ុនឡើងមក ខ្ញុំនៅជាមួយតាពីនជាប់ណាំ ។

ប៊ូលីៈ នៅជាមួយតាពីន?

ភីមៈ បាទ! នៅជាមួយតាពីន ។

ប៊ូលីៈ តាពីនក្រែង៩២០?

ភីមៈ ទេ! ៨០១តា ។

ប៊ូលីៈ ៨០១ ។

ភីមៈ ពីដំបូង ។

ប៊ូលីៈ ហ៊ូ! ពីដំបូង ។

ភីមៈ ដល់ក្រោយមកទេបានទៅ៩២០នេះ ។

ប៊ូលីៈ ក្រោយមកទៀត?

ភីមៈ ចុះមកនេះហើយ!

ប៊ូលីៈ ឆ្នាំណាពូចូល៩២០?

ភីមៈ ទេ! បងមិនដឹងឆ្នាំណាទេ ។

ប៊ូលីៈ ចុះមកត្រពាំងប្រាសាទហើយ ឬនៅ?

ភីមៈ ដូចថានៅក-៧ចាស់ ហ៊ើ! ក-៧ថ្មីទៅ ។ ខ្ញុំភ្លេចបាត់ហើយ កាលហ្នឹងនោះណា ។

ប៊ូលីៈ ពេលហ្នឹងនៅដីថៃ ឬក៏ចុះមកដីខ្មែរយើងហើយ ដែលគេដូរមក៩២០នេះ តាពីន?

ភីមៈ កាលហ្នឹង?

ប៊ូលីៈ បាទ!

ភីមៈ វាពិបាកថាដូចថាមិនចំណាំដែរណា ។

ប៊ូលីៈ តាម៉ុក ឈូសផ្លូវជាំស្រងាំមកក្រោម ឬនៅកាលហ្នឹង?

ភីមៈ ទេ! មិនដឹងឈូសពីខែណាទេ! ខ្ញុំអត់ដឹងដែរ ។

ប៊ូលីៈ អត់ដឹងដែរ ៩០តាម៉ុក ចុះមក ដើមឆ្នាំ៩០ ។

ភីមៈ ខ្ញុំកាលហ្នឹង ខ្ញុំមកចុះ គ្រួសារគេហ្នឹងអត់ទៅនាដីថៃទេណា កាលហ្នឹងខ្ញុំចូលទៅក្នុង ។ ដល់ខ្ញុំបកពីក្នុងមកវិញ កម្លាំងគេចុះពីអន្លង់វែងមកទៅហើយ ។

បូលី៖ ហ៊ូ! ចឹងពេលគេបែកមកអន្លង់វែងពូចុះមកនៅក្នុងទេ?

ភីម៖ បាទ! ចុះពីដីថៃមកក ចុះ! ខ្ញុំអត់នៅក្នុងនោះទេ ។

បូលី៖ ឥលូវ ខ្ញុំសូមសួរពូរឿងចូលទៅក្នុងតិច ពូធម្មតាកម្លាំងខ្មែរក្រហមនៅលើភ្នំមិនចឹងហ៉េពូ? ១០០១, ១០០៣ចឹងណា

ភីម៖ បាទ!

បូលី៖ ខាងនេះគេមានកងតាសូហុង, តាសុខភាពអីចឹងទៅ ខាងនេះមានតាមាស មុត ចឹងទៅនៅខាងកោះកុងណាពូ ហើយពូនៅនេះ១០០១! មិនគេបញ្ជូនកម្លាំងចូលទៅធ្វើការតាមខេត្តមិនចឹងហ៉េ?

ភីម៖ បាទ!

បូលី៖ ចឹងពេលពូចុះឡើងៗ ប៉ុន្មានគ្រលប់ ប៉ុន្មានដង?

ភីម៖ ចុះភ្នំនេះ?

បូលី៖ បាទ! ចុះពីលើភ្នំ ទៅធ្វើការនៅក្នុង ចុះប៉ុន្មានដង?

ភីម៖ បើថានិយាយចុះ មិនដឹងជាប៉ុន្មានទេ ពិបាកថាណាស់ បើថាចឹងណា! ខ្ញុំនិយាយតិចក្នុង១ឆ្នាំចុះទៅ១ឆ្នាំ បានខ្ញុំឡើងមកម្ដង ។

បូលី៖ ចុះទៅ១ឆ្នាំ បានឡើងទៅភ្នំម្ដង?

ភីម៖ បាទ! បានឡើងទៅភ្នំម្ដង ។ ម្ដងកន្លះខែហ្នឹង ចុះទៅវិញហើយ! ចុះទៅវិញ១ឆ្នាំ បានឡើងមកទៀត ។ លើកលែងតែថាជិតៗទេណា បានវា(ស្ដាប់ពុំបាន) មករហូតដែរ ។ ៤ ទៅ១០ថ្ងៃ បានគេមកម្ដង បើថាទៅដល់កំពង់ចាម កំពង់ធំ ទៅ១ឆ្នាំ ទម្រាំមកដល់ ។

បូលី៖ មកធ្វើអី?

ភីម៖ អត់ទេ! មិនមកធ្វើអី មកជូនណាទៅមេរៀនសូត្រណា បានមេៗរៀនសូត្រទៅជូនណា គេមកចឹងតែម្ដង បានហើយមកជួបជុំគ្រួសាររបស់កូនចៅណាម្ដងទៅ ១០ថ្ងៃ កន្លះខែទៅ បានគេប្រមូលកម្លាំងទៅវិញទៅ បាទ! ពីណាឈឺក៏ឈឺទៅ ពីណាជាក៏ជាទៅណា វាមិនកំណត់ទេអារឿងឈឺគ្រុននោះ ។ នរណាឈឺទៅដេកពេទ្យទៅ!

បូលី៖ ឥលូវពូចុះទៅធ្វើការនៅខេត្តណាខ្លះកាលហ្នឹង?

ភីម៖ ខ្ញុំមួយជំនាត្រប់ ខ្ញុំទៅធ្វើការដល់កំពង់ធំ!

បូលី៖ កំពង់ធំនៅស្រុកអី?

ភីម៖ ស្រុកស្ទោង ស្រុកនេះឯង ។

បូលីៈ ស្មោនក៏ស្រុកដែរ?

ភីមៈ ហើយឪពុកខ្ញុំក៏ធ្វើនៅតាមអាដែង ជាយៗណា តាមផ្លៀក ស្រម៉អីយើងហ្នឹង ។

បូលីៈ បារាយណ៍ សន្ទុក ស្មោន ។

ភីមៈ អត់បានចូលដល់ក្នុងទេ ធ្វើការនៅតែផ្លៀក ស្រម៉ និងខាង(ស្តាប់ពុំបាន) ពូទៅនេះដែរ ។

បូលីៈ ពូទៅធ្វើការនៅកំពង់ធំនេះដែរ?

ភីមៈ បាទ! ទៅដែរតា ។

បូលីៈ ចឹងពូចេញពី១០០១ មកកំពង់ធំចឹង?

ភីមៈ បាទ! ខ្ញុំនេះឯង មកដល់ក្រោមហើយនេះ នៅលើកំពង់ធំ ។

បូលីៈ ក្រៅពីកំពង់ធំ ពូទៅធ្វើការនៅឯណាទៀត?

ភីមៈ ខ្ញុំទៅអាដែង ខាងកំពង់ចាម ។

បូលីៈ កំពង់ចាមទៀត?

ភីមៈ បាទ! ខាងស្រែកក់យើងនោះណា ។

បូលីៈ អានេះ កំពង់ធំណាពូ អានេះកំពង់ចាម! កំពង់ចាម ពូធ្វើការនៅស្រុកណា?

ភីមៈ មិនដឹងស្រុកណា នៅឯម្តុំស្រែកក់យើងហ្នឹង ស្រែវែងនោះ ប៉ុន្តែមិនដឹងស្រុកអី ខ្ញុំអត់ស្គាល់ទេក្នុងស្រុកនោះ ។

បូលីៈ អត់ស្គាល់ដែរ!

ភីមៈ នៅតាមជាយៗណា ស្រែកក់ហើយរែសវែងហ្នឹងណា ខ្ញុំនៅធ្វើការនៅនោះឯង ខ្ញុំនៅតាមមេនោះ មានតាមពីណា តាមមេៗ! មេទៅទីណា ខ្ញុំទៅទីហ្នឹង ។

បូលីៈ ចឹងមានកំពង់ធំ កំពង់ចាម មានទៅធ្វើការនៅទីណាទៀតទេពូ?

ភីមៈ អត់មានទេខ្ញុំនោះ ។

បូលីៈ រតនៈគិរី មានដែលទៅទេនោះ?

ភីមៈ អត់ទេ! ខ្ញុំអត់ដែលទៅទេនោះ ។

បូលីៈ មណ្ឌលគិរី?

ភីមៈ អត់ទាំងអស់ ។

បូលីៈ តែពីរ! មានតែកំពង់ធំ និងកំពង់ចាម?

ភីមៈ មិនដែលទៅទេ រតនៈគិរី! មិនដែលហ្នឹងឃើញផង ។

បូលីៈ យើងទៅហ្នឹង យើងទៅនៅក្នុងព្រៃទេ យើងមិនទៅក្នុងភូមិទេ?

ភីមៈ បាទ! ជួនណាចូលក្នុងភូមិម្ដងៗណា ។ ជួនណាទៅនៅមួយថ្ងៃវាល់ល្ងាច ក៏មានដែរភូមិណា មិនកំណត់ទេ ។ បាទ! នៅក្នុងភូមិហ្នឹងឯង ហូបបាយ ហូបទឹក ក្នុងភូមិអន្លុយលេង ប្រជាជនក្នុងភូមិមានអី បើសភាពការណ៍មិនស្រួលទេ ចូលក្នុងព្រៃទៅ ។ ចេញពីព្រៃមកនៅក្នុងភូមិក្រែងប៉ះពាល់គ្នា ប៉ះប្រជាជន ។

បូលីៈ ដែលប៉ះជាមួយយួន ជាមួយរដ្ឋាភិបាលទេ?

ភីមៈ ប៉ះ!

បូលីៈ វាយគ្នា គឺលចឹងទៅ?

ភីមៈ បាទ! ជាមួយសមរភូមិបក្សចឹងទៅណា ។

បូលីៈ ផ្ញើក ស្រម៉?

ភីមៈ ផ្ញើក ស្រម៉ នៅពណ្ណរាយណា ។

បូលីៈ បាទ! ភូមិអីគេ?

ភីមៈ ភូមិផ្ញើក ស្រម៉ ។ ។

បូលីៈ ស្រុកអីគេ? ស្រុកស្ទោង?

ភីមៈ មិនដឹងស្រុកអីគេ! ខ្ញុំមិនដឹងទេ ។

បូលីៈ ស្រុកស្ទោង ។

ភីមៈ បាទ! ស្រុកស្ទោង ស្រុកអីដឹង ។

បូលីៈ ស្រុកស្ទោងហ្នឹង វាជាប់ជាមួយព្រំដែនព្រះវិហារ ហើយជាប់ជាមួយសៀមរាបដែរ ។

ភីមៈ បាទ! អាហ្នឹងហើយចឹងអីនោះ ។

បូលីៈ ក្បែរដីក្រែងណា?

ភីមៈ បាទ! អាហ្នឹងនោះឯង ជាប់គ្នានោះ ។

បូលីៈ ប្រពន្ធពូ នៅកំពង់ធំដែរ?

ភីមៈ នៅកំពង់ធំតា?

បូលីៈ ស្រុកអីគេ ប្រពន្ធពូ?

ភីមៈ ស្រុកអីនៅឃុំត្រដិត មិនដឹងស្រុកអី!

បូលីៈ វាមានបារាយណ៍ ស្រុកសន្ទុក ស្រុកប្រាសាទសម្បូរ ស្រុកបល្ល័ង្ក ស្រុកស្ទោង កំពង់ស្វាយ ។

ភីមៈ កំពង់ស្វាយទេដឹង?

បូលីៈ	កំពង់ស្វាយ!

ភីមៈ	គេហៅឃុំត្រដែត ឃុំគេខ្ញុំហៅតែប៉ុណ្ណឹងឯង ។

បូលីៈ	តែអត់ស្គាល់ស្រុក ណុំពូណុំ?

ភីមៈ	បាទ! អត់ស្គាល់ស្រុកទេ ។

បូលីៈ	ហើយ១ឆ្នាំ គេឲ្យឡើងមកម្តង?

ភីមៈ	បាទ! ១ឆ្នាំ ម្តង?

បូលីៈ	ពេលដែលពូចូលទៅធ្វើការ ការហូបចុកអី ពីណាគេអ្នកផ្គត់ផ្គង់ ខាងលើអី ឬក៏រកខ្លួនឯង?

ភីមៈ	គេបើកលុយឲ្យណាបង?

បូលីៈ	បើកលុយឲ្យ?

ភីមៈ	បាទ! ឥលូវឧទាហរណ៍ថា ចុះពីភ្នំមកណា ចុះពីភ្នំមកមានកងពលគេណា មានកងពល ដូចថាតាសារឿនចឹងណា តាសារឿននោះកាន់កាប់លុយហ្នឹងណា កាន់កាប់ហើយដល់ពេល១ខែ គេបើកម្តង ។ ១ខែ ហៅមេៗមក មកដល់កន្លែងគេបង់លុយឲ្យ បើកលុយ ឧទាហរណ៍ថាគ្នា១០នាក់ចឹង បើកលុយឲ្យគេឲ្យលុយក្នុង១ខែៗ ទិញអង្ករ ។

បូលីៈ	បាន ប៉ុន្មានម្នាក់?

ភីមៈ	ម្នាក់ គេមិនកំណត់ទេបង ជួនណាទៅបាន១០០បាត! ចឹងទៅ ខ្លះ៧ ទៅ៨០០ចឹងទៅ ជួនណាប្រើមាសចឹងទៅ មាសសន្លឹកណា ពីមុន អស់ពីមាសទៅ ប្រើលុយទៅ ជួនណាប្រើសារុងទៅ ជាមួយប្រជាជនណុំ ដូរសារុងទៅ ។ សារុងម្នាក់ ៤ទៅ៥ គ្រាន់ដូរអង្ករហូបតាមផ្លូវទៅ វាមិនទៀតទេចឹងនោះ ។ គេថាដើរសុំប្រជាជន!

បូលីៈ	ពេលអស់ទៅណុំ!

ភីមៈ	បាទ! ពេលអស់ទៅ ។ ដាច់ពេលនោះ សុំទៅមួយកំប៉ុងៗ ប៉ុណ្ណេះៗមួយចាននោះ ដាក់ទៅ ជួនកាលទៅ(ស្តាប់ពុំបាន) ។

បូលីៈ	ចុះគ្រាប់ពីណាគេអ្នកផ្គត់ផ្គង់គ្រាប់?

ភីមៈ	គ្រាប់កាលហ្នឹង កាលតស៊ូ មានពីណា ទិញមកពីចិន ។

បូលីៈ	អត់ទេ! និយាយថាពេលពូចុះមកពីចិន មកធ្វើការនៅកំពង់ធំ កំពង់ចាម នរណាគេអ្នកដឹកគ្រាប់ដឹកអីពីលើភ្នំមកឲ្យពូ?

ភីមៈ អត់ទេ! ដឹកខ្លួនឯងៗ បើថាជំនាន់នេះណា ឧទាហរណ៍ថាគ្រាប់រំសេវកម្លាំងជាប់ចុះមកជញ្ជូន ខាងនេះមួយសារៗ បើថា១០០នាក់ ឬក៏២០០នាក់ មកដាក់ស្រេច! មកដាក់ព្រៃសាកៗ

បូលីៈ អ៊ូ! បើថាគេយកមកដាក់ព្រៃសាកហ្នឹង?

ភីមៈ បាទ! បើថា១០០នាក់ ឬក៏២០០ក្តី មានB-40,41 តាមកាំភ្លើងដែលយើងកាន់ៗ អាកាបីងត្រឡោកអីហ្នឹង កាំភ្លើងអីយើងកាន់មកទាំងអស់ មកទម្លាក់ព្រៃស្អាកហ្នឹងៗ

បូលីៈ ហើយបាន បញ្ជូនពីហ្នឹង បញ្ជូនបន្តពីក្រោមទៀត?

ភីមៈ ពីភ្នំនេះមក បានមកទន្លេសាប ដល់ពេលថាហ៎ អ្នកដែលចុះមកមួយសារហ្នឹងទៅ ម្នាក់គ្រាប់គាត់ថាបើការយួរមួយរួច អត់មានថាកំណត់ទេៗ ហើយខ្លួនឯងយកប៉ុន្មានយកទៅ ចឹងគេក៏(ស្តាប់ពុំបាន) យកមិនរួចហើយ ប៉ុន្តែអ្នកដែលកាន់កាំភ្លើងតូចត្រូវកាន់កាំភ្លើងធំមួយ គ្រាប់បេណា ត្រូវកាន់កាំភ្លើងមួយ ឬមីន១គ្រាប់ ទៅ២គ្រាប់! ៦៩អីទៅ មីនស្គរអីទៅតាមនោះឯងៗ

បូលីៈ ចុះនៅកំពង់ធំ នៅកំពង់ចាមអត់មានតំបន់ស្តុកគ្រាប់ទេពូ ឬក៏មានតំបន់គេស្តុកចែកចាយជាក្រុមតូចៗ?

ភីមៈ អត់មានទេ! បើយក២ៗសារទៅ គឺចែកគ្នាទាំងអស់ ដើរមកយកទាំងប៉ុន្មាន នរណាខ្លះប៉ុន្មានយកដែលច្រើនប៉ុន្មាន អ្នកមកខាងហ្នឹង មួយគ្រាប់ពីគ្រាប់ បីគ្រាប់ចែកតែយប៉ុណ្ណឹងឯងអស់ហើយ គ្រាប់វាតិចនោះៗ

បូលីៈ ព្រៃស្អាកវានៅនេះ នៅឆ្ងាយដែលណាពូ? អាកំពង់ចាម វាដើរប៉ុន្មានខែហើយ?

ភីមៈ ឆ្ងាយណាស់ មិនតិចទេៗ

បូលីៈ ចឹង បានខ្ញុំចេះតែគិតថាក្រែងលោ មានឃ្លាំងស្តុកនៅកំពង់ធំ នៅកំពង់ចាម ហើយកងដែលធ្វើការ នៅកំពង់ចាមនាំគ្នាមកពីហ្នឹងទៅ?

ភីមៈ អត់មានទេ!

បូលីៈ អត់មានទេ!

ភីមៈ បាទ! លាក់បន្តិច បន្តួចណា(ស្តាប់ពុំបាន) ជញ្ជូនកម្លាំងមនុស្សដែរប៉ុន្មាន តិចតួច ដូចថាបណ្តោះអាសន្នទៅណា កុំឲ្យវាទៅឆ្ងាយពេកឡើងភ្នំ ចុះភ្នំឆ្លងកាត់តំបន់ច្រើនណាស់ចឹងឯងៗ កាត់បន្ថយខ្លះៗ បើថាដល់ក្នុងហើយ គ្មានគ្រាប់លាក់ទេ តាមកាលហ្នឹងទៅរៀងៗខ្លួនប៉ុណ្ណឹងឯង គ្មានអីទេៗ

បូលីៈ ចុះពេទ្យហ្នឹងទៅយ៉ាងម៉េចទៅពូ?

ភីមៈ ពេទ្យអី! ពេទ្យមានធម្មតា សឺរ៉ូមអីថ្នាំពេទ្យ គ្មានអីទេ។ ត្រូវគ្រុនត្រូវឈឺ ត្រូវអី ត្រូវចាក់ ត្រូវលេបអី ដាច់ជើងដាច់ដៃ ចាក់ថ្នាំអី ថ្នាំអីធម្មតាអីអត់ពិបាកទេ។

បូលីៈ ពេលយើងនៅធ្វើការនៅក្នុងហ្នឹង ពេលយើងត្រូវរបួសមានពេទ្យអីដែលទេពូ?

ភីមៈ មានតា! ពេទ្យគេតាមដាប់។

បូលីៈ ពូការឆ្នាំប៉ុន្មានពូ?

ភីមៈ ហ៊ូ! ខ្ញុំពិបាកថាណាស់ ភ្លេចបាត់ហើយ ការប៉ុន្មានទេ។ យូរដែរ ខ្ញុំការនៅក-៧នេះឯង។ ក-៧ ជង់ទង់នេះឯង មិនដឹងប៉ុន្មាន! ខ្ញុំអត់ចាំដែលកាលហ្នឹងនោះណា។

បូលីៈ ការនៅក-៧ហេ៎?

ភីមៈ បាទ!

បូលីៈ ពេលហ្នឹង ពូឡើងមកលើវិញហើយ ហើយពេលការហើយពូទៅក្រោមទៀត ឬក៏លែងបញ្ជូនហើយពេលការហើយ?

ភីមៈ នៅបាន ប៉ុន្មានខែទេកាលហ្នឹង។

បូលីៈ នៅបានប៉ុន្មានខែដែរ ការហើយ។

ភីមៈ ទេ! នៅចង់១ឆ្នាំដែលការហ្នឹង ចុងឆ្នាំ យូរដែលហ្នឹង។

បូលីៈ នៅខាងលើនេះ?

ភីមៈ បាទ! គាត់ហ្នឹងអត់ថាម៉េចទេ វាស្រលាញ់ខ្ញុំណា៎! ប្រពន្ធគាត់ណា ជួនណាខ្ញុំចូលទៅក្នុងទៅ ជួនណាពិបាកឯក្រោយពេក ធ្វើសំបុត្រ ឬនិយាយតាមគេអូទៅ។

បូលីៈ នរណាស្រលាញ់ពូ?

ភីមៈ យាយរិន ប្រពន្ធតាពីនហ្នឹង។

បូលីៈ ហ៊ូ! យាយរិន ប្រពន្ធតាពីន?

ភីមៈ បាទ! ឈ្មោះយាយរិន។

បូលីៈ គាត់ចូលចិត្តពូហី?

ភីមៈ បាទ! ស្រលាញ់ខ្ញុំណាស់។

បូលីៈ ម៉េច បានចឹងពូ?

ភីមៈ ទេ! មិនដឹងជាម៉េចទេ ខ្ញុំពិបាកថាណាស់ មប្យ៉ាងថាខ្ញុំអ្នកធ្វើផង។ កាលនោះ មានដុតធ្យូងណា ដុតតែអុស។ ធ្យូងខ្លះដែរ អុសខ្លះដែរ! ធ្វើការ(ស្តាប់ពុំបាន)ខាងមុខក៏ខ្ញុំធ្វើ ហើយខាង

ក្រោយក៏ខ្ញុំធ្វើៗ ខ្ញុំធ្វើគ្មានរើសរើសអើងវណ្ណៈទេ បាយក៏ខ្ញុំដាំ ហើយសស្លក៏ខ្ញុំស្ល ប៉ុន្តែឆ្ងាញ់ មិនឆ្ងាញ់ មិនដឹងទេ ។

បូលីៈ ហើយពួហៅខ្ញុំមកលើវិញ?

ភីមៈ បាន១ ទៅ២ខែរហូត! គាត់ចុះទៅវិញទៅ ។

បូលីៈ ពេលការហើយ ចុះទៅ ចុះទៅធ្វើការនៅខេត្តណា?

ភីមៈ ពិបាកណាស់ ខ្ញុំចុះទៅនៅ!

បូលីៈ នៅកំពង់ធំ ឬកំពង់ចាម?

ភីមៈ នៅកំពង់ធំ ។

បូលីៈ កំពង់ធំវិញ?

ភីមៈ បាទ!

បូលីៈ ការហើយគេនៅតែឲ្យចុះទៅទៀតបឹង?

ភីមៈ យ៉ាងយូរ២ ទៅ៣ខែហ្នឹង ។

បូលីៈ ពេលហ្នឹងនៅ៨០១នៅឡើយ ពេលដែលការហើយ?

ភីមៈ ការហើយក៏នៅ៨០១ដែរ នៅក្បែរ៨០១ហ្នឹង ។

បូលីៈ មីង៨០១ដែរ?

ភីមៈ បាទ!

បូលីៈ ចុះមីងនៅខាងក្រោយ ធ្វើអីដែរមីង?

ភីមៈ អត់មានធ្វើអីទេ ។

បូលីៈ មានជញ្ជូនគ្រាប់ឲ្យគេទេ?

ភីមៈ អត់ទេ! មានកូន មានចៅយូរហើយ ។ ទោះបី បើថាជញ្ជូនគ្រាប់ នៅលីវទាំងអស់ ។ ពេលមានប្រពន្ធ មានប្តីហើយលែងជញ្ជូនទៀតទេ ។

បូលីៈ ចុះបិតចម្រូង?

ភីមៈ អត់មានបិតទេនៅលើភ្នំនោះ ។

បូលីៈ អត់ទេ!

ភីមៈ ទើបតែខ្ញុំចុះមកទេ បានបិត ទើបតែចុះមកដីខែណាទេបានបិត ។ ខ្លះចុះដល់អន្លង់វែងហើយ បានបិត បើតាមនៅលើភ្នំ គ្មានបិតទេ នៅលើភ្នំនោះ ។ បិទស្រោលក់ឲ្យថៃ លក់ទៅ ។

បូលីៈ ហ៊ូ! មានរកស៊ីដែរ កាលហ្នឹង ។

ភីមៈ បាទ! រកស៊ីៗ រកស៊ីលួចលាក់ណា យួនគេចាប់ណា៎ ចាំមើលតែយើង គេព្រៃចូលទៅក្នុង គេខំរកស៊ីទៀតទៅណា គេប៉ះពាល់គេ ដូចនេះទៅលួចលាក់ស្រាទាំងកាដុងៗទៅ ស្ពាត់តាម អូរត្រាវបឹងទៅៗ ពីម្ដុំអូរត្រាវមក តាមផ្លូវ ដើរតាមផ្លូវបេះណា គេដឹក គេឃើញយើង គេយកស្រា នៅប៉ុណ្ណោះឯង ខ្ញុំឃើញជួនកាល លក់ទៅៗ

បូលីៈ ហើយយើងបានអីបិតទៅ?

ភីមៈ អង្ករ!

បូលីៈ ប៉ុនមាន ឡ មានអីបិតទេ?

ភីមៈ ទេបិតតែឆ្នាំង ឆ្នាំងយើងគេដំដូចប៉ោត បិតដាក់ទុយោ ដាក់អំពង់ឈើទៅ មានអីបិតស្រួល ដែលតា ប៉ុន្តែវាមិនបានច្រើនដូចគេណាៗ យើងយកឆ្នាំងនេះទៅដាក់ទៅ ដាក់នៅលើឆ្នាំង រួចទៅគេបិត គេបុកបាយ ជាមួយកន្ទក់ទៅ កុំឲ្យវាចេញផ្សែងហុយណា ហើយគេចាក់ទឹក ទៅ ហើយនេះគេដាក់ទុយោទៅ ត្រង់នៅខាងនោះៗ

បូលីៈ ប្រើមេដមបែរ?

ភីមៈ បាទ! មេដំបែរៗ

បូលីៈ ហើយពេលណាដែលពូដាច់ដើងពូ?

ភីមៈ ដាច់ ខ្ញុំនៅភ្នំនេះៗ

បូលីៈ ភ្នំណា?

ភីមៈ នេះខាងកើតព្រះប្រឡាយ អានោះខ្ពស់ៗ

បូលីៈ ភ្នំដោះក្រមុំ?

ភីមៈ ម្ដុំអូរ៥០ ៗ

បូលីៈ អូរ៥០ អេ៎?

ភីមៈ បាទ!

បូលីៈ នៅខាងកើតដោះក្រមុំទៀត?

ភីមៈ បាទ!

បូលីៈ អូរ៥០ ភ្នំដោះក្រមុំនៅខាងនេះៗ ពូមើលឃើញទេ? នេះឈូករុនណា៎ នៅពីឈូករុន ហួសទៅតិច ភ្នំដោះក្រមុំ?

ភីមៈ ឈូករុនហ្នឹង ខាងកើត វាមានមួយទៀតណា អាវៀងលយមកខ្ពស់ណាៗ នៅខាងកើតមួយ ទៀតៗ

បូលីៈ	អូរ៥០ហ្នឹងហេ៎?

ភីមៈ	បាទ!

បូលីៈ	ពូជាន់មីននៅហ្នឹង?

ភីមៈ	នៅកន្លែងខ្សែលីងយួនហ្នឹង

បូលីៈ	ខ្សែលីងយួន?

ភីមៈ	បាទ! គូទពិលប៉ុណ្ណេះៗ

បូលីៈ	គូទពិល?

ភីមៈ	បាទ! ប្រវែងនេះៗ ចេះវាតិច គូចពិលនោះ យកទឹកឲ្យគេ ទឹកពីរកានៗ

បូលីៈ	ឲ្យនរណា?

ភីមៈ	ឲ្យទៅអ្នកដូសេត! អ្នកដូសេត នៅអន្លុយមួយកាដុង ដូសេតមួយកាដុង ហើយទឹកមិនមែន នៅអូរ៥០ទេអី?

បូលីៈ	ចឹងហ៎?

ភីមៈ	បាទ! ដញ្ជូនពីក្រោមមកវិញ លើភ្នំ សុទ្ធតែគោងវល្លិ៍លើភ្នំលើគេនោះៗ

បូលីៈ	ខាងលើនោះអត់មានទឹកទេពូ?

ភីមៈ	បាទ! នៅលើអត់មានទេៗ

បូលីៈ	ចឹងយើងចង់បានដឹកទឹកអី ទាល់តែចុះទៅអូរ៥០ ៗ

ភីមៈ	ផ្ទាស់វេនគ្នា! ផ្ទះ៦នាក់ ៣នាក់នៅចាំខ្ទូសេតពើយនេះ ៣នាក់ទៅនៅឯក្រោមនេះៗ

បូលីៈ	បើយនេះ ពូចង់និយាយថាពើយឈូករុននេះហេ៎?

ភីមៈ	អត់ទេ! ខាងកើតនោះៗ

បូលីៈ	ខាងកើតឈូករុនទៀត?

ភីមៈ	បាទ! ខាងកើតឈូករុនទៀតៗ

បូលីៈ	ក្បែរអូរ៥០នោះ?

ភីមៈ	បាទ!

បូលីៈ	ឬក៏អត់ដល់ទេ?

ភីមៈ	អាពើយនោះ ឡើងទៅចុះទៅ អូរ៥០នៅឯក្រោមៗ ជិតបន្ទាយថៃ ឯក្រោយនោះ បាទ! ឡើងតាមបន្ទាយថៃឈូករុនហ្នឹង ដើរទៅមិនមានអូរ១ៗ ដើរទៅក្រោមចេះរហូត ដល់ចម្ការ ម្ចាស់គេនោះ គេហៅចម្ការម្ចាស់ៗគេនោះ ចម្ការម្ចាស់នៅម្តុំនោះឯងៗ ៣នាក់នៅចាំខ្ទូសេត

៣នាក់នៅឯក្រោម ។ ព្រឹកឡើង ដញ្ជូនទឹកឲ្យគេ  ប្អូនកាន! កានប៉ុណ្ណេះណា ។ ឡើងមក ទុកឲ្យគេមក យកចុះទុកទៅវិញ ។ បីថ្ងៃ ផ្លាស់គ្នាម្តង! ដូចថា ខ្ញុំនៅអូរ៥០នោះឡើងមក ចាំនៅខ្ទូសេតតែម្តង ២នាក់ចុះទៅទីនោះម្តង ។ បីថ្ងៃនោះអត់បានផ្ទុតទឹកទេណានៅលើ ។ មានទឹកឯណាមុជ មានតែទឹកផឹក ដាំបាយគ្រាន់ហើយ ។ មានតែទឹកដាំបាយប៉ុណ្ណេះឯង មានតែទឹកដាំបាយហើយហ្នឹងផឹក ប៉ុណ្ណេះឯង ។ បាន៣ថ្ងៃបាន យើងចុះមកមុជទឹកនៅក្រោមនេះណា ផ្លាស់ប្តូរគ្នាណា ឡើងមកនេះមានព្រំ មានភួយលែងមុជទឹកម្តងហើយណា អត់ទឹកហើយមួយៗថ្ងៃ ។ ហើយវាអត់ធ្វើអីដែរណា បាទឃើញតែអង្គុយនៅស្ងៀមនៅថ្មចឹងទៅ ។ ទៅស្តាប់ទៅ ស្តាប់ដូចថាអ្នកក្នុងៗណា បានស្តាប់ទៅសម្លេងទាហានខាងណាៗ ខាងណាគេចុះខាង អង្គុយស្តាប់លើថ្មនោះទៅចុះឯង មិនដឹងការងារអីនោះទេ គេផ្លាស់ក៏ផ្លាស់ៗមក ។

បូលីៈ ចុះស្រីក្មេងៗ បានអីមុជទឹក?

ភីមៈ ក្មេងៗ?

បូលីៈ បាទ!

ភីមៈ អត់មានក្មេងទេ! នៅទាហានតែម្តង ។

បូលីៈ ទាហានសុទ្ធតែម្តង?

ភីមៈ បាទ!

បូលីៈ ចឹងអ្នកដែលនៅតាមជុំវិញដូចក-៧ ចង់កអីបានទឹកណាមុជ?

ភីមៈ បាទ! គាត់នៅកន្លែងគេមានទឹកច្រើន ។

បូលីៈ កន្លែងផ្សេង ។

ភីមៈ នៅកន្លែងប្រជាជន កន្លែងគេរស់កន្លែងទឹកណា ។ ដល់កន្លែងទាហានចេះ ជួនកាលទៅខ្វះទឹកក៏មាន ពេលណាអត់ក៏មានដែរណា ។ វាមិនទៀងទេ កន្លែងណាអត់ កន្លែងណាមាន ខ្វះទៅក៏ដញ្ជូនមក កម្លាំងតិចណ៎ ដញ្ជូនបានមួយព្រឹក ។ ប៉ុន្តែទឹកនោះជួនណាអត់បានមុជទេ បើវាឆ្ងាយមុជឯណា ចុះវាឆ្ងាយនោះ ជួនណាទៅ៣ថ្ងៃនោះ បានដូរគ្នាគេទៅមុជម្តងទៅនោះ ។ អ្នកឡើងម្តងនេះ អត់ទឹកម្តងហើយ បានទឹកផឹក និងដាំបាយប៉ុណ្ណេះឯង អត់អីទេ ។

បូលីៈ ហេតុអី បានជាពូជាន់មីន យ៉ាងម៉េចទៅពេលហ្នឹង?

ភីមៈ យួរទឹកឲ្យគេ ។

បូលីៈ យួរពី អូ៥០ហ្នឹងឡើងមក?

ភីមៈ បាទ!យកឲ្យគេកន្លែងខូសេតហ្នឹង?

បូលីៈ ហើយយ៉ាងបាន ដាដាន់?

ភីមៈ ផ្លូវវា២ ។ ផ្លូវមកពី អូ៥០មក មានផ្លូវ១ ផ្លូវដើង ចុះតាមឆ្លងកាត់ស្រែវានោះណា អាមួយនោះស្ពានវា អាមកពីនោះមកវាត្រង់ ដើរតាមផ្លូវនេះ ផ្លូវក្រោម បើមកពីនោះ ផ្លូវត្រង់ឆ្លងស្ពាន កាលហ្នឹងផ្លូវដើរពល់ថ្ងៃ ខែ៤ ។ ខែ៤ ខែ៥ ថ្ងៃ១ អ៊ូ!ខែ៤ ថ្ងៃ១ ។ ខ្ញុំដឹងច្បាស់ណាស់ ។

បូលីៈ ខែ៥ ថ្ងៃ១?

ភីមៈ បាទ! ខែ៥ ថ្ងៃ១ ។ ឆ្នាំ២០០០ ទេ៩៥ហើយណា ។

បូលីៈ ក្រែង៩៥ ចុះមកខាងក្រោមនេះហើយ?

ភីមៈ បាទ! ខ្ញុំចុះមកនេះហើយ ។

បូលីៈ អ៊ូ! ចឹង ។

ភីមៈ បាទ! ខ្ញុំចុះមកដីខ្មែរហើយ ។

បូលីៈ ចុះមកម្ដុំណា?

ភីមៈ កម្លាំងនោះដូចខ្ញុំ ថាម៉េញនោះ កន្លែងអូរ៥០នោះ ។

បូលីៈ អូរ៥០ហ្នឹង ។

ភីមៈ បាទ! ហ្នឹងមកលើពើយណា ។ មីង១នៅអូរស្វាយនោះ!

បូលីៈ ចុះមកអស់ហើយណ៎?

ភីមៈ បាទ!

បូលីៈ ប៉ុន្តែកម្លាំងទៅលើភ្នំវិញ?

ភីមៈ ចុះបើប្រធានបុកតាមនេះដែរ ភាគច្រើន តាមវាល តាមប៉ុស្តិ៍ ហើយរថក្រោះមកតាមនោះ មកតាមទ្រាំពង ។

បូលីៈ ទាហានរដ្ឋាភិបាលនោះ ។

ភីមៈ បាទ! មកតាមទ្រាំពងនោះហើយខ្ញុំ ហើយខ្ញុំនៅទល់មុខហ្នឹងឯង ខូសេតនៅត្រង់នោះឯង ។ បើមិនឡើងភ្នំឯណា បើមីង១នៅអូរស្វាយឯនោះ បាទ! នៅឆ្ងាយដែរ ។ ហើយខ្ញុំឡើងឆ្នាំនេះផ្ទះខ្ញុំតាំពី៩៣ទីនេះ ។ ដល់វា(ស្តាប់ពុំបាន) អុកឡុកនេះទៅ ជម្លៀសទៅនោះ មីង១ទៅនោះទៅ ។ ទៅនៅអូស្វាយនៅនោះទៅ! ហើយកម្លាំងទ័ពនៅធ្វើការនោះដែរ ។

បូលីៈ អ៊ូ! ដោយសាររដ្ឋាភិបាលវាយខាងនោះពេក?

ភីមៈ បាទ!

បូលីៈ កាលហ្នឹងបោះឆ្នោតចឹង?

ភីមៈ បោះហើយ៩៣នោះ! បោះហើយតា ៗ

បូលីៈ ចឹង! តា ប៉ុល ពតទៅនៅក្បាលទម្សោងហើយចឹង?

ភីមៈ បាទ! គាត់នេះហើយ ៗ កាលពីបោះឆ្នោត ខ្ញុំនៅអន្លង់វែងនេះទេ! ៩៣ណា ៗ

បូលីៈ បាទ!

ភីមៈ ដល់ក្រោយមក កម្លាំងតា០៥នេះ បានប្រមូលកម្លាំងពួកខ្ញុំមក៨១២នោះ បបួលមកខាងនេះខ្លះ បាននៅទីនេះ ពួកខាងបឹងប្រជុំណា បឹងប្រជុំនៅឯទួលនោះ ៗ នៅដីដីខាងទួលសព្វថ្ងៃនេះ ៗ នៅខាងមួយជុំ នៅកងមួយជុំហ្នឹង នៅខាងនោះមួយជុំផ្ទះ តាម៉ុកបេះទៅនោះ ៗ មិនមែនតាម៉ុក ធំទេណា តាម៉ុក យាយអុចនោះ ៗ

បូលីៈ តាម៉ុកអីគេ?

ភីមៈ តាម៉ុកយើង នៅកំពង់ធំនេះ!

បូលីៈ ឈ្មោះតាម៉ុកដែរ?

ភីមៈ បាទ! ឈ្មោះតាម៉ុកដែរ ៗ

បូលីៈ ធ្វើអីតាម៉ុក ហ្នឹង?

ភីមៈ មានធ្វើអីគាត់ ធ្វើទាហាន ៗ

បូលីៈ ទាហានសាមញ្ញា មិនមែនមេទេ?

ភីមៈ អត់ទេ! មិនមែនទេ គាត់ទាហានធម្មតា(ស្តាប់ពុំបាន) មឹងជញ្ជូនទៅ ជូនកាលបញ្ជូនទៅអូរស្មាយទៅ ក្មេងៗនៅធ្វើការតាមនេះទៅ ខ្លះចាំលើភ្នំទៅ ហើយខ្លះទៅអូរកាប់ខ្លាណា ស្រេចតែគេដាក់ទៅណា ៗ បាទ! អូរស្មាយបេះទៅៗនោះ ទៅធ្វើការនោះទៅ!

បូលីៈ ខ្ញុំសុំសួរកាល៩៣ កាលបោះឆ្នោតពោលពូនៅអន្លង់វែងណា? ពេលហ្នឹងគេឲ្យយើងបោះឆ្នោតទេនៅអន្លង់វែង?

ភីមៈ អត់មានបោះទេ!

បូលីៈ អត់មាបោះទេណ៎?

ភីមៈ បាទ! អត់មានបោះទេ! ដោយសារជំនាន់នោះគេរើសណា ៗ គេរើសឯងធ្វើខាងអ៊ុនគាត់គេរើស ធ្វើខាង ខាងខ្ញុំគេរើសតា ៗ

បូលីៈ ពូមានទៅធ្វើអីអ៊ុនគាត់គេទេ?

ភីមៈ អត់ទេ ។

បូលីៈ អត់ទេណ៎?

ភីមៈ គ្មានទៅទេ ។

បូលីៈ ប៉ុនពេលដែលគេរៀបចំបោះឆ្នោតហ្នឹង ខាងក្នុងគេមិនបោះឆ្នោត ។ ខាងអន្លង់វែង យើងមានបានទៅបោះហ្នឹងគេទេ?

ភីមៈ គ្មានបោះទេខ្ញុំ ។

បូលីៈ អត់សោះតែម្ដងណ៎?

ភីមៈ បាទ! បើក្រែងគេមិនដឹង ខ្ញុំអត់ដឹងណា៎ បើមិនដឹងផង មិនដឹងមិនព្រួទេ អត់ដឹងទេកាលនោះ ។

បូលីៈ អ្នកផ្សេងគេបោះ? ដូចជាកន្លែងតា៥១៩ អីគេបោះ?

ភីមៈ បាទ! អត់ដឹងទេ ។

បូលីៈ ដូចថាកន្លែងគេបោះ ប៉ុនគេនៅខាង បន្ទាយមានជ័យឯនេះណា ។

ភីមៈ បាទ! នៅឆ្ងាយ ។

បូលីៈ ចឹងពេលដែលពួយូរទឹកនោះមក ក៏ជាន់មីនហ្នឹងទៅ?

ភីមៈ បាទ! ឡើងមកជាន់ ដល់តែជាន់ទៅ មិនទាក់ទៅ ហើយតាសឿន ហ៊ិន នៅត្រពាំង សព្វថ្ងៃនេះ(ស្ដាប់ពុំបាន) គាត់ឡើងមកដល់ ខ្ញុំជាន់ហើយ គាត់ស្រឡាំងកាំងគាត់មើលមិនដឹងគាត់ថាមីនចាស់ ឬក៏មីនថ្មី? ខ្ញុំទេមិនដឹង! គ្រុនបាត់ហើយហ្នឹង រត់ទៅបាត់នៅឯក្រោយ ខ្ញុំស្រែកហៅតា ។

បូលីៈ មីនផ្ទុះហ្នឹង?

ភីមៈ នៅស្ងឹងត្រែងតា ។ ដល់ខ្ញុំ ស្រែកហៅហ៊ូៗ ។

បូលីៈ ស្រែកហៅថាម៉េច?

ភីមៈ ហ៊ូតាអើយតាៗ មិនចាស់ប៉ុន្មានទេ ប៉ុន្តែគេបង្ខំណា ចាស់ជាងខ្ញុំ ថាម៉េច ឯងនិយាយថាម៉េចអា៎ ចុះខ្ញុំមានថាម៉េច បើជាក់គូថអន្តុយហើយ បើផ្ទុះទៀតក៏ស្លាប់ដែរ ប៉ុន្តែមីនរៀចកាលនោះអត់ចំ ។ ប៉ុន្តែដល់គាត់ ថាយកក្រម៉ាទៅទុក ក្រម៉ាតាឯងនោះ ដូចថាសម្គុតគាត់ណា រកម៉ានៅរុំកនោះ ។ គ្រាន់តែរុំកក្លាម ខ្សែក មកចង(ស្ដាប់ពុំបាន) គាត់នៅនេះហើយណាអញទៅហៅគេ ។ គាត់ទៅហៅគេហើយ បានខ្ញុំទៅឡើងនៅលើថ្ម! ដេកនៅលើថ្មទៅណា៎ ប្រហែលជាម៉ោង១០ព្រឹក ម៉ោង១០ថ្ងៃ ដេកនៅលើថ្មឡូប្រងាង ហើយមួយទៀតខ្ញុំ នឹកឃើញទៅថាមិនរស់ទេ ។ មានដំរុំនៅនៅក្រោមនោះ ពេទ្យគេមានដែរ ពេទ្យគេមិនទាន់មក

ប្រហែលជា១ម៉ោង ឲ្យត្រជាក់ដៃនៅទីនេះ។ ត្រជាក់ៗដៃ បើអាដៃមក អូយ!ឈាម ឈាមប្រវែងនេះ ដូចម្ជុល ម្ជុលស្អី! ខ្ញុំចាប់ដកមកឡើងប្រវែងនេះ ចំត្រង់នេះ។ ប៉ុនម្ជុលតែម្តង។

បូលីៈ អំបែង?

ភីមៈ អត់អំបែងទេ! ចាប់ដកមកក្តុច។

បូលីៈ ជាប់នៅហ្នឹងដៃហ្នឹងហេ៎?

ភីមៈ បាទ! ដកមកឈាមរ៉ៃ! ដកមកទាញអាដៃអាវក្របួចជាប់ ដេកនៅជីងខ្នួននៅឡើងទេ អាហ្នឹងនោះ។

បូលីៈ នៅជីងខ្នួនទេ អន្ទុយ ឬក៏ដេក?

ភីមៈ អន្ទុយនៅលើថ្ម។

បូលីៈ ពូ?

ភីមៈ បាទ!

បូលីៈ ហើយដើងយ៉ាងម៉េចដើង?

ភីមៈ នៅដាក់បញ្ឈរហ្នឹង។

បូលីៈ បញ្ឈរយ៉ាងម៉េច?

ភីមៈ អត់ទេ! ដាក់សន្ទូកចេះឯង។

បូលីៈ អត់មានឈរចេះទេណ៎?

ភីមៈ ឈរណាកើត បើចុកដើង រោយ។

បូលីៈ ក្រែងគេថាកុំឲ្យហូរឈាម គេត្រូវចងឡើងលើចេះ កុំឲ្យហូរឈាមខ្លាំង?

ភីមៈ បាទ! កុំឲ្យហូរឈាមខ្លាំង។

បូលីៈ ប៉ុន ពូដាក់ផ្តេកចេះទេ?

ភីមៈ ដួនណាផ្តេក ដួនណាលើកកាន់ណាបើវាចុក វាចុកដើងនោះ ប៉ុនតាដែលថាបស្រាត់ឈ្មោះ តាអី?

បូលីៈ ឈ្មោះតាសឿន?

ភីមៈ បាទ!

បូលីៈ ហើយតាសឿននោះ គាត់យកក្រម៉ាងចងការ៉ូឲ្យ?

ភីមៈ បាទ! គាត់ហែកក្រម៉ាចងការ៉ូ។

បូលីៈ ចង់ត្រឹមណា?

ភីមៈ ត្រឹមនេះ ។

បូលីៈ ត្រឹមកជើង ។

ភីមៈ ដាច់ដែរ ប៉ុន្តែដាច់តិច សរសេសរសៃណា! ព្រោះមីនតែប៉ុណ្ណេះទេ ដាច់តែតិចទេ គ្រាន់តែជាន់មីនពីប ខ្ញុំអ៊ុកគូថញាច់ បាត់ការ បាត់កាំភ្លើអស់រលីង ។ លើកជើងម្ខាងនេះឡើងចុមដាច់អស់រលីង បាទលើកម្ខាងទៀតចុមដាច់អស់ ក្រៅពីនេះដោះស្បែកជើងក្រវាត់ចោលប្រុច!

បូលីៈ ដាច់តែម្ខាងទេអី?

ភីមៈ បាទ!

បូលីៈ ខាងនេះអត់អីទេ?

ភីមៈ អត់អីទេ ។ ដោះក្រវាត់ចោលហ្នឹង ស្បែកជើងក៏បាត់ អាទឹកក៏បាត់ ទៅទីណាត់ទីណែងអស់រលីង អាពេទ្យគេមកពីក្រោម គេកាប់ ឈើចង់ត្បែងអីណាអីណីមក ។ ឡើងជាប់ណាត្បែង! វាថាមកឈាមនោះ មកដេក១ថ្ងៃ មួយយប់ហើយថែម១ថ្ងៃទៀត ចាំអាថៃឡើងមកអត់ព្រ គេអូរ គេបិទគេអូរបាត់ គេចុះបើព្រ ។ ដល់នេះទៅយប់ហើយ ក៏ចុះមកតាមផ្លូវនេះមក បានខ្ញុំរបូតធ្លាក់មកអូរស្វាយ ។ ដល់អូរស្វាយហើយអាត្រាក់ ដល់អូរឫស្សីដាក់ឡាន ពីត្រឹមនេះទៅអូរឫស្សីណាំដាក់ឡាន ឡានទៅអូរស្វាយ ទៅអន្លង់វែងដាក់អាត្រាក់ទៀត ។

បូលីៈ យកទៅមន្ទីរពេទ្យអន្លង់វែង?

ភីមៈ បាទ!

បូលីៈ ពេលដែលពូជាន់ហ្នឹង គ្នាពូមានប៉ុន្មាននាក់?

ភីមៈ ៦នាក់ ។

បូលីៈ ៦នាក់?

ភីមៈ បាទ!

បូលីៈ ជាន់តែពូម្នាក់ឯងទេ?

ភីមៈ បាទ! ៦នាក់ហ្នឹង ។ ២នាក់ ដូចថាខ្ញុំថាមិញហ្នឹង ឈ្មោះតាសឿន ។ ហ្នឹង មកដឹកជញ្ជូនជាមួយខ្ញុំ នៅភឿនផ្ទះនេះណា អានេះគេនៅឯក្រោម ។

បូលីៈ អ៊ូ! តាភឿននៅឯក្រោមទឹក?

ភីមៈ អត់ទេ! គាត់នៅចាំផវាន់នោះ ចាំកៅស៊ូនៅក្រោមនោះ ។

បូលីៈ ដល់ពូឡើងមកលើ?

ភីមៈ ខ្ញុំឡើងយកទឹកឲ្យគេ យកទឹកឲ្យគេ ហើយទៅចុះវិញ ។ មិនទាន់ចុះទៅវិញណាផ្ទុះមីនទៅ!

បូលីៈ ចុះទៅវិញ ជាន់មីនបណ្ដោយ?

ភីមៈ ឡើងមកផ្ទុះណា ។

បូលីៈ ឡើងមកជាន់មីនតែម្ដង?

ភីមៈ ឡើងមកជាន់មីនបណ្ដោយ?

បូលីៈ ពេលដែលឡើងមក ឡើងគ្នាប៉ុន្មាននាក់?

ភីមៈ ឡើងមកតែ២នាក់ទេ ។

បូលីៈ ពីរនាក់តាសឿន?

ភីមៈ បាទ! ប៉ុន្តែកម្លាំង៣នាក់ទៀត គេនៅកន្លែងនោះទេ នៅ១ប៉ុន្តែស្លាប់បាត់ហើយ ដូចថាស្អីបុក ម៉ូតូ ជិះម៉ូតូបុករនុ៩មូលផាប់បាត់ហើយស្រវឹង ។ ឈ្មោះភឿននោះណា ។ ឈ្មោះភឿនដែរ ប៉ុន អាមួយភឿន ផាត់ ហើយមួយ ភឿ ពៅ ។

បូលីៈ ភឿន ដូចគ្នា! នៅចាំក្រោមឯនោះ?

ភីមៈ ចាំឯក្រោមនេះ ។

បូលីៈ ហើយពូនៅពីរនាក់តាសឿន ឡើងមកលើ?

ភីមៈ បាទ!

បូលីៈ ហើយ៣នាក់នៅចាំកន្លែងពើយណ៎?

ភីមៈ បាទ! អាសលនេះមួយ ឈ្មោះអាសល ផ្ទុះនេះ! ផ្ទុះក្រហមមួយ ហើយទៅខាងនោះពេទ្យ នោះមួយ បីនាក់ និងតាសឿននោះមួយទៀត បាទ!ឥលូវស្លាប់បាត់ហើយ ។ គ្នា៦នាក់ទាំង អស់ ។ បីនាក់ហ្នឹង បីនាក់ជាប់តែម្ដង ផ្លាស់វេនគ្នាបីថ្ងៃម្នាក់ ដល់វេនខ្ញុំនោះចេះទេ ខ្ញុំដឹបូង យល់សប្ដិផ្ទួនៗគ្នា យល់សប្ដិឃើញគ្នា កូនតាពីននេះណា ឲ្យត្របែកខ្ញុំហូប ។ ត្របែក ខ្ញុំថាអត់ស៊ីទេ ខ្ញុំថាចឹង អត់ស៊ីទេ ត្របែកខ្ចីនោះណា ខ្ញុំអត់មែន! ដល់យប់មួយទៀត គេឲ្យអាវសពាក់ ទាំងសជ្រែក មកស្បោងថ្មីថែស ។ អាវស គាត់ថានែក៎យកអាវមួយពាក់ ទៅ នៅទាំងស្បោងប្រូកទៅណា ។ ចុះអាវសជ្រែកនោះ ពាក់ទៅទេស្អាតតា! ដល់មិនបាន ប៉ុន្មានក៏ភ្ញាក់! យល់សប្ដិដូចជាមិនល្អសោះ ដល់យប់ទៅភ្លើឆេះបណ្ដោយ ៣យប់(ស្ដាប់ពុំ បាន) ។

បូលី៖	ភ្លើងឆេះ?

ភីម៖	បាទ! ឆេះ ទាហានបាញ់នោះណា៎ ។ ខ្ញុំនៅលើ ឈរចំអាកន្លែងមីនណា៎ ជីងខ្លួនណា ។ ខ្ញុំដេកយល់សប្តិនៅចំអាកន្លែងមីនហ្នឹង ។ ហើយឃើញទាហានបាញ់ឯក្រោម ប្រជាជននោះរត់ អាទាហានោះបាញ់ ។ បាញ់ប៊ិម ឆេះនៅនោះស្រែប្រាំង ឆេះអណ្តាតឡើងលិចផ្ទះ លិចដំបូលបាត់ឆេះ ហើយប្រជាជនចាក់ទឹក ចេះដើរចាក់រំលត់តាមក្រោយ មិនដឹងម៉េចទេភ្លើងឆេះ ។ ដល់ព្រឹកឡើងមកជាន់អាកន្លែងនោះឯង ឈរទល់បណ្តោយ១យប់ ។

បូលី៖	ពេលយើងជាន់នោះផ្ទុះភ្លាម ឬក៏ជាន់ហើយដឹងខ្លួន?

ភីម៖	ទេ! អត់ដឹងទេ ។

បូលី៖	អត់ដឹងទេណា៎?

ភីម៖	បាទ! ជាន់ដាច់ ភីង! តែម្តងណា ។ ព្រោះអាគិបនោះវានៅ អានេះគល់អំពិល កប់នៅឯក្រោម កប់ពីក្រោម អា(ស្តាប់ពុំបាន) នៅពីលើ ហើយមានអាម្ជុលពីលើមួយទៀត ។ ម្ជុលហ្នឹង ហើយអាគ្រាប់ម្ជុលមានភ្នែកមាន់វា ដូចគិបដូចជា(ស្តាប់ពុំបាន) ជាន់ដាច់ អាគ្រាប់ចេះវាបុកអាភ្នែកមាន់នោះ ទៅប៉ះអាគ្រាប់នោះឆេះ ។

បូលី៖	បុកហើយផ្ទុះភ្លាម អត់មានទាល់តែដកជើងហើយផ្ទុះភ្លាមទេ?

ភីម៖	អត់ទេ! ដូចគ្រាប់កាំភ្លើង យើងណា ។ គេចុចគ្រាប់ហើយ គឺពឹង! បណ្តោយ មានដឹងអីអត់ដឹងទេ ។

បូលី៖	ដោយសារមីនហ្នឹងតូច បានជានៅសល់ត្រឹមកជើង?

ភីម៖	បាទ! តូចទេ មីនតូចអំពិលណា ។

បូលី៖	មីនស្គរ?

ភីម៖	មីនស្គរគ្រែលហើយណា៎! មីនស្គរធំជាង តូចអំពិល ។ តូចពិលតែប៉ុននេះទេ ដូចក្តិតពិលម៉េចចឹងហើយ ។

បូលី៖	ហើយមីនហ្នឹង នរណាគេអ្នកកប់?

ភីម៖	ទេ! យួន ។

បូលី៖	មិនមែនយើងទេ?

ភីម៖	ដីវាដកទ័ពហើយមួយជំនាន់យើង យើងដកនោះណា ដកហើយកប់ឲ្យគាពាស ពេញទឹកពេញដី បើវាទៅហើយ ហើយកប់ឲ្យពេញ ។ សម្បូរណាស់លើភ្នំ កប់ឲ្យពេញ រាប់ពាន់ឡាន ។ បាទ! មានតិចឯណា អាខ្លះទៅមានឃ្លាំង ឯណា ឃ្លាំងឯនេះ ខ្លាំងបាក់អស់ហើយ

ខ្ញុំដើរប៉ះណា៎ ខាងព្រះប្រឡាយ ឈូករុននេះ ហើយភ្លើងឆេះ ផ្ទះតែមីនទេ មិនដឹងខ្លះ ឬក៏គ្រាប់ ខ្លះបេ ចោលណា ចឹងឯង ។ ហើយបើមីន ដាក់មិនចេះតិចទេមីន ។

បូលីៈ យើងដែលដាក់ទេយើង?

ភីមៈ ដាក់! ដូចថា ពេលយើងនៅ យើងដាក់ការពារនៅឯក្រោយណា ដាក់ផ្លូវប្រែកអត់ទេ អត់អីទេ បើថាការពារផ្លូវក្រោយ តាមផ្លូវអីទៅ ដាក់ដែរ ប៉ុន្តែវាឆ្ងាយ ពេកណា ។

បូលីៈ ដាក់ហ្នឹង យើងមានដែនទីអីចំណា របស់យើងទេ?

ភីមៈ ដាក់ជាខ្សែ ។

បូលីៈ ដឹងទេថាយើងដាក់នៅម្តុំហ្នឹងអី?

ភីមៈ ដឹង! បាទ! មាន(ស្តាប់ពុំបាន) ។ ឥលូវ ឧទាហរណ៍ថាដាក់មកខ្សែ ត្រឹមណាដូចថា ដើមឈើនេះ ដួនណាដូចជាតាំងខ្សែទៅចេះទៅ ។ ដល់ស្នែកឡើង ដក់យកទៅដាក់ទំ ដល់ ឃើញមិន ចំណាំដើមឈើនោះ កាច់មែកខ្លះទៅ កាប់មែកឈើ កាប់មែកឈើរសន្ទុះវា ទៅ ។ ស្អែកឡើង យកទៅដាក់នៅឯក្រោយឯនោះ ២០ ទៅ៣០ម៉ែត្រពីរក្រោយ ។ ប៉ុន្តែ មីនឆ្នៃទេ មិនមែន មីនឯណា ។

បូលីៈ ពេលដែលពួផ្ទុះមីនហ្នឹង ពេលដែលតាសឿនចងការ៉ូឡូពួហើយ រត់ហៅគ្នា?

ភីមៈ អត់ហៅទេ! គាត់ ភ័យគាត់ណា មានគ្នាណាបើកម្ញាំងនេះនៅឯនេះវិញ លែងខ្ញូសេតទៅវិញ ណា ហើយកម្លាំងតាភឿននោះ នៅអូ៥០នោះ!

បូលីៈ ធ្វើយ៉ាងម៉េចទៅបានគេមកយកពួបាន?

ភីមៈ អត់ទេ កម្លាំងតាមទៅយកណាតាសឿន ។

បូលីៈ តាសឿនទៅតាម?

ភីមៈ តាសឿនទៅតាមកម្លាំងគេនៅនេះ នៅខ្ញូសេតនេះ ។

បូលីៈ ចឹងទុកពួចោលសិន?

ភីមៈ មានណាតែ២នាក់! មាននរណានៅ នៅតែនោះឯង ទុកចោល ។

បូលីៈ ហើយពេលហ្នឹងពួសន្លប់ទេពេលហ្នឹង?

ភីមៈ អត់អីទេ! ខ្ញុំអត់សន្លប់ទេពេលហ្នឹង ។

បូលីៈ អត់សន្លប់ទេ?

ភីមៈ បាទ!

បូលីៈ ដឹងឈឺទេ?

ភីម: ទេ! វាមិនសូវប៉ុន្មានទេ ។ គេសែងមក មកដូចធម្មតា មិនអីទេ ។

បូលី: គេសែងពីលើភ្នំចុះមកក្រោម?

ភីម: បាទ!

បូលី: ចុះមកតាមណាឈូករុន?

ភីម: ដំបូងចុះមកអូរ៥០នោះ

បូលី: បាទ!

ភីម: អត់មានចុះមកផ្លូវត្រង់នោះទេ ទៅអូរ៥០នោះ ភ្នំចេះ ។ អូស!វហែកអស់អង្រឹងមួយ ។

បូលី: អូសយ៉ាងម៉េច?

ភីម: អន្តិលៗ តាមភ្នំណា! មិនមែនអូសរូដូចក្របី ដូចគោណា ។ បាទ! ដាក់ទៅអន្តិលតិចៗទៅណា ទៅភ្នំចោទចេះនោះ ។ អ្នកខ្លះទៅទ្រនៅឯក្រោម ចុះមានផុតណា ខ្ពស់! ដល់ចឹងទៅចេះតែផុតតិចមកៗ អូសតិចៗមក ពីលើចេះតាម បានផុតចេះតែតាមទៅ ទល់គ្នាសែងទៀត ។ ប៉ុន្តែមិនស្រួលទេ នៅលើថ្មរហូត នៅលើភ្នំនោះមិនដឹង ។

បូលី: ចុះមិនរយះ គួថស្លាប់បាត់ហើយ?

ភីម: អត់អីទេ! រហែកតែអង្រឹង ។

បូលី: រហែកតែអង្រឹងទេណ៎?

ភីម: បាទ! រហែកតែអង្រឹង អង្រឹងរហែកតែរយៃ ។ អង្រឹងចិនដង ស៊ិតតិចណា ។

បូលី: ប៉ុន្មាននាក់អូស?

ភីម: ទាំងអស់គេសែង! ៤នាក់ទេ បាទ! ៤នាក់ទេ គេសែង ដូរគ្នា ព្រោះអីកម្លាំងដែលចាំនោះវាបីនាក់ណា ហើយកម្លាំងទៀតនោះដែលយកទឹកពីរទៀត ខ្ញុំរាប់ហើយខ្ញុំដាច់ដើងនោះ ។ បាទ! ថែមតាសឿនមួយទៀត បាន៤នាក់ ។ ហើយម្នាក់នោះនៅរស់ នោះ! ៦នាក់ទាំងអស់នោះ ។

បូលី: ចឹងសែងពីកន្លែងដាំមកណា?

ភីម: មកអូរ៥០នោះ ។ ចេញពីអូរ៥០ទៅនៅកន្លែងបន្ទាយថៃនៅក្រោមនោះ ។ កន្លែងថៃបន្ទាយវា នៅអាជិត កន្លែងអូរនោះណា ជិតស្ពាននៅអូរ៥០ ។ ដូចថា(ស្តាប់ពុំបាន) ថ្ងៃត្រង់ចឹង ម៉ោង១០ មកដល់ហ្នឹង១ថៃ មកយប់ហ្នឹង១ថ្ងៃទៀត គេទៅថៃវា បិទគេអូរនោះ ។ ដល់តែបិទគេអូរ នោះទៅ គេក៏មិនចូលរហូតទាល់តែព្រលប់ៗ គោះសែងយកមកក្រោមមក ដល់សែងមក ដល់ក្រោម ៨-៣ មកដល់ពីបដែរ ។

បូលី៖ ឆ-៣ យ៉ាងម៉េច?

ភីម៖ ឆ-៣ ដូចថា វាដូចទូតណា! ដូចវាចង់វាមានទូតណា ។

បូលី៖ អ្នកថៃហ្នឹងហ៎?

ភីម៖ បាទ! ខាងនេះគេហៅ ឆ-៣ ហ្នឹងណា ។

បូលី៖ ហូរចឹងមុនដំបូងប្រឹង សែងពូទៅថៃទេចឹង?

ភីម៖ និយាយទៅណា ។

បូលី៖ ដឹកយកទៅ?

ភីម៖ ដឹកទៅព្យាបាល?

បូលី៖ នៅឯថៃនោះ?

ភីម៖ បាទ! នៅថៃ ។

បូលី៖ ប៉ុន្តែវាអត់ពុ?

ភីម៖ ប៉ុនគេហៅឆពណ៌ ។ ដូចថាឥលូវយើងហៅទូតហើយ ទូតដូចថាដាក់ យើងកិច្ចការងារអី ទាក់ទងគ្នាណ៌ ។ ឆ្លងកាត់គ្នាទាក់ទងគ្នាទៅ ទៅតាមយើងទៅ យើងបកឡើង ខាងក្រោយវា ទៅ ហើយវាចាប់ ដូចថាទូតមានចឹងឯង ។

បូលី៖ ដល់តែអត់ពុចឹង យើងសុខចិត្តមកក្រោមវិញមក?

ភីម៖ បាទ! ព្រោះយូរពេក ។

បូលី៖ សែងមកពេទ្យអន្លង់វែងនេះ ។

ភីម៖ មកដល់ក្រោម វាមកដល់ដែរ បាននរណាសែងទៅវិញ! បើខ្លួសចឹងស្លាប់ទៅហើយ ឈូករុន ក្រោមហើយនោះ វាធម្មតា មាននរណាយកត្រលប់ទៅវិញ ។

បូលី៖ ប៉ុន្មានគីឡូដី ពីហ្នឹងមក?

ភីម៖ ទេចុះភ្នំ វាស្រួលទេណាចុះភ្នំ ប៉ុនដល់សែងសែងទៅ ពិបាកណាស់ណា ។ ចុះទៅចេះហើយ ចុះមកហើយ បើចុះស្រួលតិច បានលឿនខ្លះ មាននរណាគេសែងទៅ ។ ទៅនេះវិញទៅ រហូត ទៅដល់អូរបុស្សី បានគាយន់កងពលដែលហ្នឹងណា ។

បូលី៖ កងពលប៉ុន្មាន?

ភីម៖ គាយន់កងពលប៉ុន្មាន ខ្ញុំមិនសូវដឹងដែរទេ ។ ដាក់ឡានគាយន់ទៅ ក៏ដល់ កំពង់ស្វាយ បានគេ ដាក់ មកដាក់បានទៅ អន្លង់វែងនោះ ។

បូលី៖ ចឹង២ថ្ងៃ?

ភឹមៈ បាទ!

បូលីៈ ទម្រាំដល់អន្លង់វែង!

ភឹមៈ បាទ! ២ថ្ងៃ ២យប់ៗ គាត់ដេកនៅបន្ទាយថៃ២យប់ មកដល់នេះទួលពង្រនេះ ២យប់ទៀត ព្រឹកឡើងទៀត ចាំមួយថ្ងៃវាល់ល្ងាចទៀត (ស្តាប់ពុំបាន) ជិតៗដែរហ្នឹង ។

បូលីៈ ហើយទៅដល់គេកាត់បណ្តោយហ្នឹង?

ភឹមៈ គ្រាន់តែទៅដល់ដាក់សឺរ៉ូមពីប គេឲ្យទៅដេកប្រង់ការនោះ ហើយគេដាក់សឺរ៉ូម គេដល់កំណត់ម៉ោងគេណាស់ៗ ដល់ដាក់សឺរ៉ូមហើយ ហើយគេថាចាប់ផ្តើមធ្វើការ គេចាប់កម្រើកប្រូក ខ្ញុំទប់ជាប់ ដឹងតែប៉ុណ្ណឹង បន្ទាប់មកលែងដឹងអីបណ្តោយ ។

បូលីៈ គេចាក់ថ្នាំសន្លប់?

ភឹមៈ បាទ! គេដាក់ក្នុងសឺរ៉ូមណា! គេដាក់នៅក្នុងសឺរ៉ូមស្រេចៗ ខ្ញុំមាត់ធម្មតាចឹងឯង អត់មានអីទេ ស្រាប់តែគ្រូគេថា ដល់ម៉ោងហើយ ។ គ្រាន់តែដល់ម៉ោងហើយ ពេទ្យគេមកព្រឹបតែម្តងចាប់ក្របួចខោខ្ញី ខ្ញុំទប់ជាប់បាត់ដឹងខ្លួនបណ្តោយ អត់រលឹង ដឹងតែខ្លួនឯងដឹងតែប៉ុណ្ណឹង រហូតដល់គេកាត់ហើយអីហើយ គេយកមកដាក់នៅមន្ទីរថ្មីទៀត ដាក់អាគ្រែថៃ គ្រែរលួយ ទើបក៏បានឈរក៏បាននោះ ដាក់អានោះហើយ បានដឹងខ្លួនឡើងមក ។

បូលីៈ ដឹងខ្លួនឡើង អស់ជើងបាត់?

ភឹមៈ អស់ជើងបាត់ គេកាត់ជើងបាត់ ។

បូលីៈ មានអារម្មណ៍យ៉ាងម៉េចទៅ?

ភឹមៈ ទេ! មានអារម្មណ៍ធ្វើម៉េច បើវាចឹងទៅហើយ ខ្ញុំចេះតែមានដែរ ប៉ុន្តែនិយាយលែងចេញទៅហើយ ។

បូលីៈ មានអារម្មណ៍ស្តាយជើងទេ?

ភឹមៈ ស្តាយចេះតែស្តាយហើយជើងនោះ ។

បូលីៈ មានយំទេពេលហ្នឹង?

ភឹមៈ អត់មានយំកាលហ្នឹងនោះ ។ គ្មានទឹកឃើញស្តាយៗ តែប៉ុណ្ណោះឯង ។

បូលីៈ ពេលដែលជាន់មីន មានដឹងថាខ្លួនត្រូវតែកាត់ជើងចោលទេ?

ភឹមៈ បាទ! ខ្ញុំគិតថាកាត់ហើយ ។

បូលីៈ ដឹងចឹងដែរណ៎?

ភីមៈ បាទ! ដឹងថាទីកាត់ ទី២មិនដឹងងាប់ មិនដឹងថារស់ ព្រោះពេទ្យវាឆ្ងាយ ។ ពេទ្យ មានដែរ ប៉ុន្តែថ្នាំ វាមិនគ្រប់គ្រាន់ណា ។ បានតែសសឺរ៉ូម ៣ទៅ៤កំប្លោកទេនោះ ។ ហើយថ្នាំលាយ ខ្លះបញ្ចូលខ្លះទៅណា ។

បូលីៈ កាត់ត្រឹមណាលោកពូ?

ភីមៈ ត្រឹម ។

បូលីៈ សោយតិចបានទេ?

ភីមៈ ត្រឹមនេះ! បើភ្លាម ប៉ុនេះឯង ព្រោះខ្ញុំឃើញដល់ទីនេះឯង ។ ដល់យើងចងការ៉ូទៅប៉ុន្មានថ្ងៃ ៣ថ្ងៃ ។ ២ថ្ងៃ ២យប់ ដល់ភ្លេចចងការ៉ូទៅវាឡើងខ្មៅ!

បូលីៈ វាអស់សាច់បាត់ហើយ ។

ភីមៈ វាដាំឡើងលើ ពេទ្យថាកាត់ត្រឹមនេះហើយ ព្រោះមេរោគឡើងដល់លើហើយ បាទ! ហើយ ចឹងមានអីទៀតខ្ញីហើយ ។ ថាទៅប្រហែលជា១តឹក ប៉ុនមិនដែលបានណា(ស្តាប់ពុំបាន) មិនថាម៉េចទេ (ស្តាប់ពុំបាន) គ្មានពេលទំនេទេ! មិនដឹងថាម៉េចទេ នរណាមិនស្គាល់ខ្ញុំនោះ និយាយមិនអួតទេ អ្នកដើងល្មមមិនដល់ខ្ញុំទេ និយាយអួតតិចហើយ មិនដូចអ្នកខ្លះទេណា មិនមែនទូរទៅទេណា ប៉ុន្តែអ្នកខ្លះមួយទេ នេះខ្ញុំប្រឹងណាស់ណា ធ្វើការសព្វថ្ងៃ ។ រួមផ្សំនេះ នោះ បើមិនប្រឹង សំខាន់នោះ វាខ្មាស់គេ ទីមួយខ្មាស់គេ ទី២ទៅវាប្រពន្ធកូនឡេល្មឹមៗទៅ ឯងនេះកន្ត្រិកន្ត្រាក នឹកឃើញស្អប់ចិត្តខ្លួនឯងណា ។ បេះតែប្រឹងទៅ មិនយូរមិនឆាប់ទេ គង់ តែបានសន្សំនេះ សន្សំនោះខ្លះទៅ បេះតែទ្រាំទៅ ។

បូលីៈ សម្រាកប៉ុន្មានខែបានចេញ?

ភីមៈ ខ្ញុំសម្រាកខ្លះមួយថ្ងៃ មួយខែ ។

បូលីៈ ហ៊ូជិត១ខែ?

ភីមៈ បាទ! ប៉ុន្តែមិនទាន់ជាស្រួលបួលទេ ប៉ុន្តែខ្ញុំវាចាក់(ស្តាប់ពុំបាន) អត់មានចាក់ពេទ្យទេ បេះតែចាក់ បើមុនដំបូង មួយថ្ងៃ៣ដង ព្រឹកឡើងថ្ងៃ ល្ងាចៗ គ្រាន់តែរាងធូរហើយ បាន ១ថ្ងៃ ២ដងៗ ។

បូលីៈ ហើយពេទ្យណាអ្នកកាត់ឲ្យ?

ភីមៈ អត់ស្គាល់ទេពេទ្យនោះ ។

បូលីៈ មិនមែនតាជួនជឿនទេអី?

ភីមៈ មិនដឹងណាណីទេ! ខ្ញុំមិនស្គាល់ដែរហ្នឹង បើខ្ញុំមិនដែលទៅដល់អន្លង់ ទើបតែទៅដល់នៅពេលដែលដាច់ជើងនេះទេ មានដែលបានដើរទេនោះ ទៅដល់អន្លង់វែងមិនដឹងពេទ្យនរណា ពេទ្យណីទេ អត់ស្គាល់គេដែរហ្នឹង កាលនោះ ។

បូលីៈ បើចេញពីពេទ្យទៅខាងណាវិញ?

ភីមៈ មកខាងអូរស្វាយ ។

បូលីៈ ផ្ទះនៅអូរស្វាយ?

ភីមៈ ផ្ទះនៅអូរស្វាយ ។

បូលីៈ ចុះមកពីភ្នំ ដំបូងដែរតាម៉ុក ឈូសផ្លូវជាំស្រង៉ាំអីចុះមកហ្នឹងពូ ចុះតាមឈូករុន ឬចុះតាមជាំស្រង៉ាំ?

ភីមៈ ទេ! ខ្ញុំកាលហ្នឹងបានខ្ញុំថាពិបាកថាណាស់ ដូចនេះ ខ្ញុំចុះមកអត់មានភូមិសាស្រ្តចុះណាត្រឹមត្រូវទេ! ចុះកាត់ កាត់មកតាមភ្នំ ។

បូលីៈ ហ៊ូ! ពូចុះកាត់តាមភ្នំ និយាយទៅ ។

ភីមៈ ត្រង់ណាក៏ចុះដែរ ឲ្យតែចុះរួច ។

បូលីៈ ខុសពីមីង១ បើមីង១គេចុះតាមផ្លូវគេត្រឹមត្រូវ ។

ភីមៈ គេតាមផ្លូវនៅក្រោយ ប៉ុន្តែផែនការគេចុះ មកក្រោមហើយណា បាទ! ត្រង់ណាពួកខ្ញុំនេះចុះមកទាំងហ្វូង មានភូមិសាស្រ្តអីណាចុះមកត្រឹមត្រូវទេ ។ ផ្លូវទៅណាចុះរួច គេចុះត្រឹមហ្នឹងអានេះ ខាងទាហាន ។ ដល់ពេលគេស្រួលបួល ហើយគេវាយ ស្រួលបួលហើយជំនាន់អ៊ុនតាក់ គេរកផ្លូវមួយចុះមក ឡានមក គេចុះមកណា៎ គេចុះមកតាមសម្រួល ។ បើពួកខ្ញុំកម្លាំងទាហាន ចុះមក មួយសារមុននោះអត់មានទេ ព្រោះអីខ្ញុំឡើងពីក្នុងមក បើគេចុះមកពីអស់ហើយហ្នឹង បាទ! គាត់ចុះមកជិតអន្លង់វែងនេះហើយ ។ ខ្ញុំអត់បានឡើងទៅទៀតឯណាបានខ្ញុំចុះមក ។

បូលីៈ ពេលណាបានពូដូរពីអូរស្វាយ មកទំនប់ដាច់វិញ?

ភីមៈ ទេ! នៅនោះមិនដឹងជាប៉ុន្មានឆ្នាំទេ ។

បូលីៈ ពីដំបូងពូ មិននៅអូរស្វាយ មិនចឹង?

ភីមៈ បាទ! ពីដំបូង គេបង្ហូសមកពី អន្លង់វែងមក នៅកន្លែងខ្ញុំនេះ ។

បូលីៈ កន្លែងណា?

ភីមៈ កន្លែងហ្នឹង ។

បូលី៖ ទំនប់ដាច់?

ភីម៖ បាទ! ផ្ទះខ្ញុំនៅទីហ្នឹង ។

បូលី៖ ទួលប្រាសាទហ្នឹង?

ភីម៖ បាទ! កន្លែងយើង អ៊ុនតាក់៩៣ណាំ មកធ្វើការនៅទីនេះ ខាងព្រះវិហារនេះ ហើយហ្នឹងខាងប្រាសាទព្រះវិហារយើងនេះ ។ ដល់មានផែនការ រដ្ឋាភិបាលវាយគ្នាចឹងទៅ ជម្លៀសមីង១ទៅអូរស្មាច់ ។ អូរស្មាច់ហ្នឹង ទៅអូរស្មាច់ខាងនោះ ពួកគាត់ខាងកម្លាំងប្ដីនោះមកធ្វើការនៅទីនេះវិញដដែរ ។ ហើយដល់ចឹងទៅយើង ដល់មកផ្ដាច់ខ្លួនទាំងអស់គ្នាចឹងទៅ រត់ពីនោះមកនេះមកវិញ ។

បូលី៖ ពីអូរស្មាច់ មកទំនប់ដាច់នេះវិញ?

ភីម៖ វាយមក ទល់តែរបូត មកដល់នេះវិញ ចុះឯង ។

បូលី៖ អូ៎! យល់ហើយ តាំងទីនៅទីនេះ រហូតមក?

ភីម៖ បាទ! ហើយបែកខាងនេះ មកបែកខាងអន្លង់វែង គេទៅដីថៃវិញកាលហ្នឹង កាលតាម៉ុកនៅណា?

បូលី៖ ខាងតាម៉ុក?

ភីម៖ បាន! ប៉ុន្មានថ្ងៃ ប៉ុន្មានខែ មកវិញដដែរដូចគ្នា ។

បូលី៖ ចុះមកវិញដូចគ្នា?

ភីម៖ បាទ!

បូលី៖ ចុះពេលដែល កម្លាំងផ្ដាច់ខ្លួន វាយជាមួយកម្លាំងតាម៉ុក ហ្នឹងពូរត់ទៅណាកាលហ្នឹង ។

ភីម៖ ការដែលផ្ដាច់ខ្លួន?

បូលី៖ បាទ!

ភីម៖ ខ្ញុំនៅទីនេះឯង ។

បូលី៖ ពូនៅទំនប់ដាច់យើងហ្នឹងណាស់?

ភីម៖ បាទ! ខ្ញុំនៅទីនេះឯង ។

បូលី៖ នៅហ្នឹង អត់មានរត់ទៅណាទេគេ?

ភីម៖ បាទ!

បូលី៖ ពេលហ្នឹង កម្លាំងតាម៉ុក មានមកតាមមករករឿងអីពូទេ?

ភីម៖ តាមយ៉ាងម៉េច បើតាមកាលផ្ដាច់ខ្លួនយើងនៅនោះណា ។

បូលី៖ នៅអូរស្វាយ?

ភីម៖ បាទ! តាពីន នៅបងជុំនោះ គាត់ទៅផ្តាច់ខ្លួននៅនោះមុន មុនហើយ ។

បូលី៖ មកវិញ?

ភីម៖ កម្លាំងពួកខ្ញុំ ដល់តែចឹងហើយ គេទៅយកប្រពន្ធគេ ។ ទៅយកដល់ផ្ទះគេតែម្តង មកដល់ផ្ទះ ទើបគេជម្លៀសភូមិនៅនេះ ហើយអាប៉ុន្មានដែលជម្លៀសមិនទាន់នោះ គេទៅភ្នំទៅ ។

បូលី៖ ទៅហូណយ?

ភីម៖ ពួកតាខាងនោះគេ ធ្វើខាងនោះទៅ ខាងតាម៉ុកនោះណា យើងអត់ដឹង យើងមកខាង នោះវិញមក មកងងឹត(ស្តាប់ពុំបាន) មានតែហៅខ្ញុំនោះ បានគោមួយនឹមដែរអូស ដែលអូសអង្ករមកកុំអីគ្មានបានអីទេ យកម៉េចមករួច បើដើងទើបតែដាច់ថ្មីៗនោះ ។ បានគោមួយនឹម អូសអង្ករ អូសខោអាវ យកមកធ្វើគៀវអូសរហូតមកដល់នេះ ។

សុវណ្ណៈ ខ្សែលីង ខ្សែយ៉ាងម៉េចពូ?

ភីម៖ ខ្សែលីង ដូចអូរចឹងណាបាទ! ដូចថាគេកាត់ ហើយហ្នឹងទាហាន ។ ខ្សែលីង ជួនណាទៅទាហាន ជួនណាទៅត្រឹមចង្កេះ ជួនណាទៅត្រឹមក្បាលជង្គង់ទៅណា យើងកាប់ចល័តវាយគ្នានោះណា ។ បាទ! អាហ្នឹងគេហៅខ្សែលីង ដូចអូរយើងអូរតូចៗចឹងណា មិនខុសទេកាប់ប្រឡាយប៉ុណ្ណោះទៅវែងចឹងទៅ ដូចថាជម្រៅត្រឹមចង្កេះទៅ បានដល់ពេលថាត្រូវការវាយគ្នា គេលោតចូលតាមហ្នឹង ចល័តតាមខាងខ្សែលីងនោះ លូនតាមខ្សែលីងទៅផុតបាត់ហើយណា ។

សុវណ្ណៈ កុំឲ្យតែគេឃើញយើងទៅណា!

ភីម៖ ដូច្នេះចល័តគ្នាចឹងទៅ លូនតាមខ្សែលីងចឹងទៅ បើថានៅលើគោកវាពុំឃើញ រត់ទៅទីណាក៏ពុំឃើញដែរ ។ ប៉ុន្តែពួកខ្ញុំគ្មាននៅខ្សែលីងទេ ប៉ុនដែរខ្ញុំជាន់នោះនៅខ្សែលីងចាស់ទេណា បាទ! ខ្សែលីងចាស់ទេ បើថាពួកខ្ញុំគ្មាននៅខ្សែលីងទេ ។

បូលី៖ ពូគិតថាមនុស្សតាម៉ុកយ៉ាងម៉េចដែរ? ស្លូត ឬក៏កាច អាក្រក់ ឬក៏ល្អ?

ភីម៖ កាចតិច កាចក៏កាច! តែថាទៅគាត់ក៏មានចរិកល្អរបស់គាត់ដងដែរណា និយាយឲ្យឃើញត្រង់ទៅ ។ ត្រង់ថា គាត់សុំអីក៏បានហ្នឹង សុំអីក៏បានហ្នឹង ដូចថា ពិបាកថាណាស់ សុំលុយបានបន្តិចៗ! ជួនណាទៅ៥០០បាត ជួនណាទៅ១០០០បាត ទៅតាមតែគាត់នឹកឃើញ បេះតែហុចឲ្យទៅសុំ ។ នាឡិកា អីសុំទៅដោះចេញពីដៃភ្លាមនេះឯង ។ ប៉ុន្តែកុំនៅយូរ បើថានៅអង្គុយប្រាជ្ញជាមួយគាត់យូរៗទៅ ពីណាមកសុំទៀត ឯងដោះឲ្យគេម្តង លែងបានពាក់

ហើយ ។ រាំដូក៏ដោយ តែសុំបាន ឲ្យតែថាសុំបានទាំងអស់ គោក៏បានដែរ ឲ្យថាហានសុំ ប៉ុនខ្វះគ្នាថាមិនហានណា បើនរណាហានគេសុំគោមួយចឹងទៅ មេមួយយកមកធ្វើពូជ ទៅ យកនៅក្រោយនោះទៅ ដឹកយកទៅផ្ទះបាត់ទៅណា ។ បើថាសុំមួយនឹម ទឹមចាប់យកទៅ ហើយគោច្រើនណាស់ណា គោមានតិចណា នេះសុំខ្ញុំបានតា(ស្តាប់ពុំបាន) ពិបាកថាណាស់ខ្ញុំ ព្រោះអត់ច្បាស់ដែលណាខ្ញុំ ។ បាទ!ទេតែចាស់ហើយ ដាច់ដើងត្រឹមភ្លៅនេះ ។ ពិបាកថា ណាស់តា ។

បូលី: ចុះពេលដែលតាម៉ុក និងតា ប៉ុល ពតឈ្លោះគ្នា វាយគ្នាហ្នឹង ខាងណាខុស ខាងណាត្រូវ?

ភីម: ទេ!ខ្ញុំអត់ដឹងដែរកាលហ្នឹង ។ អត់ដឹងទេ ព្រោះឯងខាងមេៗគេផ្សេងណា ។ ខ្ញុំកូនចៅម៉េចដឹង មិនដឹងថាខាងណាខុស ខាងណាត្រូវមិនដឹងដែរ ដឹងតែប៉ុណ្ណឹង ។

បូលី: កាលហ្នឹងតាម៉ុក សម្លាប់តា ០៥,០៦ ពូយល់ថាម៉េចដែរ ពីណាខុសពីណាត្រូវ?

ភីម: ទេអាអ្នកដែលសម្លាប់គេនោះវាខុស ។ និយាយមិនសម្លាប់ម៉េច បើវា ខុស ។

បូលី: យ៉ាងម៉េច បានតាម៉ុក សម្លាប់តា០៥, ០៦?

ភីម: ពិបាកថាណាស់មើលទៅ ដូចជាមិនដឹងថាម៉េច ខាងណាខុស ខាងណាត្រូវ ខ្ញុំមិនដឹងទេ បើថា ចាប់គឺចាប់ហើយណា៎ មិនដឹងខាងណាខុស ខាងណាត្រូវ មិនដឹងដែរ ប៉ុន្តែវាចាប់អីនេះ ចាប់ អីនោះខ្សែរយៈគេដូច តានេះឯង តាពីន គាត់មិនរកចាប់! ដូចមឿនជុំអីហ្នឹង គាត់មិនរក ចាប់ ។ យកឲ្យទៅធ្វើបន្តន់ទៀតអីនោះ តា ពីន អីនោះ ។ គេចគេឲ្យទៅ ប៉ុន្មានដល់ទៅថ្ងៃ ក្រោយទៀត គេថាដែនការឲ្យទៅទាំងអស់ ទាំងប្រពន្ធទាំងកូននេះ ទៅទាំងអស់គ្នាហ្នឹងឯង ទៅទាំងអស់ ដូចគេថាផ្លូវទៅជួយច្រូតស្រូវសិន ទៅច្រូតស្រូវនៅត្រពាំងប្រាសាទនេះ ដល់ច្រូតស្រូវបានហើយ ធ្វើស្រូវបានហោយវាយកទៅទីនោះ ទើបវាទៅធ្វើផ្ទះនៅ ប៉ុនដល់ ក្រោយមក ពុកគេថាមកចាប់អីក៏គេចខ្លួនកន្លែងហ្នឹង បាទ!គេចខ្លួនឡើង ១ថ្ងៃវាល ល្ងាច (ស្តាពពុំបាន) បើថាតាពីន ខ្ញុំដឹងនៅជាមួយជិតគ្នាណា ធ្វើការជាមួគ្នា រត់ជាមួយគ្នា តាកែវអីហ្នឹង រត់ជាមួយគ្នាហ្នឹង ។ ដល់តែម៉ោង៩យប់ កាលហ្នឹងគេការកូនអាដែងនេះ តាហ៊ាងនេះណា ។ ហើយខ្ញុំទៅមើល គេការកូននោះហើយ ពេលយប់គេរាំគេរែកនោះណា ទៅជាមួយអាភាង ដល់តែបកមកវិញអ្នកផ្ទះស្ងាត់អស់រលីង ផ្ទះតាពីណា ។ គេរៀបគេឃើញ ចេកនោះមួយស្និត នៅក្រោមជណ្តើរ គេរើសស្រូវយើងអាចធ្លាក់ ដាក់កាំជណ្តើរយើង អាចធ្លាក់ ។ ម៉ោង៩ ខ្ញុំមកដល់ ខ្ញុំឡើងមើលលើផ្ទះតាពីននោះ ឃើញស្ងឹៗនោះ ភ្ជួយឲ្យ រាយ ។ ចុះគេមានរៀបចំណា ទៅបានតែខ្លួននោះ ឥវ៉ាន់ចោលទាំងអស់ ។

បូលីៈ	រត់នែក?

ភីមៈ	បាទ! រត់ៗ គេច ម៉ោង៩យប់ប្រុច! ព្រោះខ្ញុំមកវិញ គេថាគោះទៅផ្ទះទៅ កុំឲ្យគេថានៅជាន់ដានចោរដានអី ហើយយើងដឹងហើយ បានយើងចូលណាៗ បើគេចាប់អារម្មណ៍ណាខ្ញុំគ្មានយកស្អីមួយគ្រាប់ទេ ចេកមួយហូប អាចេកទុំនៅតាំដណ្តើរនោះឯង ខ្ញុំអត់បាន មានហូបអីទេៗ ថ្វីត្បិតថាខ្ញុំនៅជាមួយគាត់មែន ប៉ុន្តែខ្ញុំមិនបានអីមួយគ្រាប់ទេ គេថាគោះកុំនៅខ្លាចជាន់ដានចោរ គេថាឯងដឹងហើយ បានទៅបាត់ហើយ បានមកភ្លាមណា ក៏ទៅផ្ទះវិញទៅណា គេនៅជិតនោះក៏យករបស់ទៅៗ

បូលីៈ	ចុះគេមានគម្រោងការផ្តាច់ខ្លួន គេមានគម្រោងការនាំគ្រួសារគេទៅអស់ៗតែម្តង?

ភីមៈ	បាទ! ទាំងអស់ៗ

បូលីៈ	ទៅតាមណា?

ភីមៈ	តាមមន្ទីរស្អាកហ្នឹង ប៉ុនវង្វេងពីស្អាកប៉ុន្មានថ្ងៃហ្នឹងៗ

បូលីៈ	មិនមែនទៅព្រះវិហារទេ?

ភីមៈ	ទៅព្រះវិហារដូចគ្នា បាទ!ប៉ុណ្ណេះឯង បើមិនចូលព្រៃស្អាកតាមនេះ គេមិនស្អាក់វាយឯប់ចូលព្រៃស្អាកសិនៗ

បូលីៈ	ចូលតាមព្រៃស្អាក?

ភីមៈ	បាទ! ចូលតាមព្រៃស្អាកសិន វង្វាងតាមព្រៃស្អាកបានកាច់កគេរ ព្រៃស្អាកនោះផងអីផងបានទម្រាំដល់ព្រះវិហានោះ អត់បាយ អត់ទឹកប៉ុន្មានថ្ងៃនោះៗ

បូលីៈ	អានេះទំនប់ដាច់យើងណាតូ ព្រៃស្អាកនៅនេះ ហើយមកក្រោយយើងវិញណ៌?

ភីមៈ	បាទៗ!

បូលីៈ	បកមកផ្លូវទៅស្វាយលើនេះនែក?

ភីមៈ	កាលគេផ្តាច់ខ្លួនគេនៅអូរស្វាយតា ៗ

បូលីៈ	អូរស្វាយនៅនេះ?

ភីមៈ	បាទ! (ស្តាប់ពុំបាន) នៅអូរស្វាយ កាលហ្នឹងដែលគេផ្តាច់ខ្លួនមកៗ

បូលីៈ	ពីណាគេនៅអូរស្វាយ?

ភីមៈ	គេផ្តាច់ខ្លួនមកនោះៗ

បូលីៈ	តាជុំតាអីហ្នឹង?

ភីមៈ	កាលហ្នឹងខ្ញុំនៅអូរស្វាយតា ៗ

បូលី៖ កាលហ្នឹង គេផ្តាច់ខ្លួននៅអូរស្វាយ?

ភីម៖ បាទ! អត់ទេ គេមានវាយអូរស្វាយណា អត់ទេ! ចុះគេដេញចាប់មេនោះៗរត់មកអូរស្វាយកាលទៅនោះ ។ ហើយខ្ញុំនៅអូរស្វាយទេ មិនទាន់មកនេះទេ ។

បូលី៖ អត់រត់គេទេ?

ភីម៖ អត់មានរត់ទេ ។ រត់ណារួច បើគេទៅតែមេៗទេនោះ ហើយនិងកូនចៅនិរសាគេនោះណា ហើយខ្ញុំដាច់ជើងហើយ ម៉េចបានទៅរួចហ្នឹងគេ ។

បូលី៖ មេៗហ្នឹង គេមកព្រៃស្អាកនេះ?

ភីម៖ បាទ! គេចេញពីអូរស្វាយមកចូលខាងឃុំទទឹងថ្មី ភូមិត្រគាតនោះ ចូលព្រៃស្អាកនោះទៅ មិនដឹងជាវង្វេងប៉ុន្មានថ្ងៃ ប៉ុន្មានយប់ទេ អាខ្លះហូបមី ។

បូលី៖ ចេញពីព្រៃស្អាក ហើយ បានទៅព្រះវិហារណ៎?

ភីម៖ បាទ! ប៉ុនគេមិនដឹងជាវង្វេងប៉ុន្មានថ្ងៃទេ ខ្ញុំនៅអូស្វាយ គេចេញបីខ្ញុំផុតបាត់ហើយនោះ គេវង្វេងៗនោះ មិនដឹងណាណីៗ ខ្ញុំមិនដឹងដែរ!

បូលី៖ ហ្នឹងហើយ បានចេញមកក្រោយនេះ ចាក់មកព្រះវិហារ ប្រាសាទមកខាងកោះកេរ្តិ៍នេះ មកចូលជាមួយរដ្ឋាភិបាលនេះ ហើយពីណាគេមកមិនទាន់ ក៏ជាប់នៅក្នុងហ្នឹងទៅ?

ភីម៖ អត់ទេ! កាលហ្នឹង អត់មានគ្នាច្រើនមកនៅទេ ។ មកគ្នាច្រើនពេកក៏ពិបាកដែរ ។

បូលី៖ មកតែបន្តិច បន្តួចទេណ៎?

ភីម៖ បាទ!

បូលី៖ មកតែអ្នកដឹងទេណ៎ មកតែមេធំៗ ។

ភីម៖ និយាយរួមមេធំៗ ។ បើថាមកទាំងហ្វូងនោះ គ្មានមករួចទេ មុខជាគេស្ទាក់វាយខ្ទេចហើយណា ពួកតាម៉ុកវាយ ។

បូលី៖ និយាយចឹង លួចរត់ទេណា?

ភីម៖ លួច!

បូលី៖ មិនមែនវាយចេញទេ?

ភីម៖ ពួកតាម៉ុក មិនមែនវាយចេញ បានជាផ្លូវការបណ្តោយ មករាប់រយ រាប់ពាន់បណ្តោយ ។

បូលី៖ អានោះលួចរត់មួយៗ?

ភីម៖ រត់មកតា ។

បូលី៖ តាមកង តាមអីរបស់គេហ្នឹង?

ភីមៈ បាទ! រត់ពេញហ្នឹងបានគេចាប់ៗ បាទ! រត់គេចគា ព្រោះតែគេចាប់ បានរត់គេចមកនោះ បើគេមិនចាប់ មានអី! ផែនការគេចាប់ មកចាប់យកទៅប៉ុន្មាននេះ យកទៅធ្វើបន្ទន់លីឈើ កងពលអី អ្នកវរសេនាធំអីទៅលីឈើ សែងឈើធ្វើបន្ទន់ៗ

បូលីៈ ធ្វើបន្ទន់ យ៉ាងម៉េច?

ភីមៈ ធ្វើបន្ទន់ បត់ជើងនេះណាៗ

បូលីៈ ចឹង?

ភីមៈ បាទ! ធ្វើបន្ទន់ធ្វើអី ដល់ក្រោយមកដូចខ្ញុំថា គេឲ្យប្រពន្ធកូនទៅទាំងអស់ណា ផែនការទៅប្រូតស្បូវនៅត្រពាំងប្រាសាទយើងនេះៗ ប្រូតស្បូវហើយ បានដឹងយកទៅនោះ បានដឹងផែនការទាន់ ចាប់ផ្ដើមអត់មាននៅផ្ទះទេ កាលហ្នឹងនោះៗ នៅតែប្រពន្ធនៅតែកូនទេនោះ គាពីនេះចូលទៅក្នុងនោះ អូរក្រោយនោះ សង្ងំដេកនៅអន្លុយ មកងើតៗមើល មានឃើញ មានអីទេ ហើយក៏ចូលផ្ទះមួយភ្លែត ប្រុចទៅវិញបាត់ៗ ខ្ញុំម៉ោង៩យប់ បានចេញចេញមក បានចេញមកក្រោយទៀត ឆ្លងអូរមកក្រោយទៀត ដើរទាំងយប់ ម៉ោង៩យប់ កាលហ្នឹងបានខែភ្លឺកាលហ្នឹងៗ បានខែភ្លឺ ចេញមកក្រោយរហូត បាត់យូរណាស់ៗ

បូលីៈ ចុះពូឆ្លងកាត់តាំងពី៧៥មកខ្មែរក្រហមហ្នឹងធ្វើនៅចម្ការកៅស៊ូ ស្នួល រហូតមកភ្នំ មកដល់ឥលូវមកនេះ ពូយល់ថា ការតស៊ូ របស់ពូជាង៣០ឆ្នាំនេះ យ៉ាងម៉េចដែរពូ ពូមានដែលសោកស្ដាយទេ ឬក៏មិនសោលស្ដាយអីទេ?

ភីមៈ ទេ! ឲ្យនឹកឃើញ មិនចេះនឹកឃើញទេណាស់ ខ្ញុំសាកស្ដាយមិនសំខាន់រឿង អាអស់ជើងអស់ដៃនោះទេៗ មានតែអារឿង អស់ជើងអស់ដៃនោះ ការរកស៊ីណា ស្រុកគេរកស៊ីស្រួលខ្លះគេរកស៊ីកស្រុកឆ្ងាយ ឯខ្ញុំដើរឆ្ងាយមិនបាន បានឯណា អត់ទេ ប៉ុន្តែមិនបាន១០០ភាគរយៗ

បូលីៈ ពូមានការស្ដាយទេ ពេលដែលចូលបដិវត្តន៍ជាមួយខ្មែរក្រហម ឬមិនស្ដាយទេ?

ភីមៈ ទេ! កាលហ្នឹងឆ្នាំ៧៥ណាស់ បើមិនស្ដាយ បើគេជ្រើសរើសទៅ បើចិត្តចង់បែកពីឪពុកម្ដាយ? ឪពុកក៏(ស្ដាប់ពុំបាន) ក៏មិនចំណាប់ដែរ ដល់ថ្នាក់យំណាៗ កាលពីខ្ញុំនៅកងចល័តណា នៅអន្តភាពនោះ ខ្ញុំទៅលេងផ្ទះម្ដងៗយំប្រៀកៗនឹកខ្ញុំ ពេលខ្ញុំចេញមកក៏យំទៀត ហើយរហូតទាល់ខ្ញុំស្លាប់ទៅមានជួបណា រហូតទាល់តែថ្ងៃនេះទាំងម៉ែទាំងពុក មានបានជួបមុខណាៗ

បូលីៈ ពូយល់ថា ការដឹកនាំខ្មែរក្រហមនោះ ត្រូវឬខុសដែលដឹកនាំធ្វើបដិវត្តន៍តស៊ូអីក្នុងព្រៃក្នុងអី?

ភឹមៈ មិនដឹងត្រូវ ឬខុសអាហ្នឹង ។ រឿងខុស វាខុសហើយ! អារឿងដឹកនាំខុស ធម្មតាទេមនុស្ស ដឹកនាំគេ បើមិនដឹកនាំយើងបានគេរស់ បើបន្ទោសខ្លួនគេ គេដែលរស់កើត ។ ដូចច្នេះ អានយោបាយអាយើងនេះទៅ បានមានគ្នា ។ ធ្វើយ៉ាងម៉េចស្លាប់រស់ជាមួយគ្នា ក្នុងពេលស្លាប់រស់ជាមួយគ្នាទៅបានៗ មានគ្នា ។ គេនយោបាយគេចឹងណា នេះខាងនយោបាយគេ គេបំផុស បំផុលចឹងឯង ហើយឲ្យយើងវា មិនដឹងអីដូចថាខ្លាចដែរពឹតដែរហ្នឹង ទៅតាមគេដែរ បើមិនបេះតស៊ូហ្នឹងគេទៅ ។ បេះតែទ្រាំៗហ្នឹងគេទៅ គេថាបេះថាចុះ បេះតែនៅគ្នាទៅ ខ្លះចូលទៅវៀតពោះ ខ្លះចូលទៅដាច់ក ខ្លះដាក់គុក ដាក់ច្រវាក់ អូសណាណើ ។ ពីណាដឹង សុទ្ធតែអត់ដឹងទាំងអស់គ្នា បើនៅក្នុងព្រៃនោះព្រុគេថា បានមានពីណាដឹង គួរតែទៅក្រែងវាមែន បើមើលមិនឃើញដូចគ្នាដដែរ បើមិនទៅទៅហើយលំបាកហ្នឹងបណ្ដោយ ។ បាទ! រូបដូចរូបជន្លង់ ដេកមិនកើតមូសខាំ យប់ព្រលប់ ហើយខែ(ស្ដាប់ពុំបាន) បានកៅស៊ូណាមួយផ្ទាំងក្របណៅតាមម្ជប់ឈើរាំងភ្នំនោះដុតកាច់ មែកឫស្សីកាច់ដុតទៅមួយឈុល ។! ហើយក៏ដេកទៅ ចឹងថាបានពិបាកថាណា ។

សុវណ្ណៈ ចុះពូ ធ្លាប់ឆ្លងកាត់ តាំងពីរបបលន់ នល់ របបពាឆ្នាំ៨ខែ២០ថ្ងៃហ្នឹង ហើយការរត់តស៊ូបច្ចុប្បន្ននេះពូ ពេញចិត្តហ្នឹងជីវិត រស់នៅក្នុងរបបណាជាងគេពូ?

ភឹមៈ ទេ! ខ្ញុំនៅរបបនេហឯងស្រួលណា បើកការរកស៊ី ការរកស៊ីយើងដើរហើរទៅណាទៅណើវាមិនពិបាកណា៎ ។ បើថាពីសង្គមនោះវាយ៉ាប់ដែរណា គាបសង្កត់មនុស្សដែរណា ។ មិនថាម៉េចទេ កត់សម្គាល់ដែលពាឆ្នាំណា វាមិនពិបាកណា ដូចពីសង្គមនោះវាយ៉ាប់ដែលណា ។ គាបសង្កត់មនុស្សដែរណា៎ មិនថាម៉េចទេ គាបសង្កត់មនុស្សដែរជិនាន់ពាឆ្នាំណា៎ ។ ទោះបីជាការហូបចុកយើងក៏ដោយ ក៏ខុសច្បាប់ ខុសអីក៏គេចាប់ គេចងដែរ ខ្លះដូចជាឧទាហរណ៍គេថាប៉ុន្ដែកន្លែងខ្ញុំមិនមានទេណា ប៉ុន្ដែកន្លែងគេមាន ។ ជួនកាលដំឡូងគេនេះ យើងដាំម្ដងៗ បើដឹងថាអ្នកលួចឈ្មោះអី ឈ្មោះ“ក” “ខ” អ្នកហូប ទៅកាស់មក មួយឆ្នាំងខ្ទះមកស៊ីអស់ ។ នេះកន្លែងគេណា បើកន្លែង ខ្ញុំគ្មានទេ កន្លែងខ្ញុំរៀងធូររឿងម្ហូបអី អើបើថាយើងដាំយើងអត់បានហូបទេ ហូបទាំងអស់គ្នាបានហូប ។ បាទ! ដូចថាខ្ញុំនិយាយផងដែរ បើថាដូចជាខ្នុរ ដាផ្លែដឹកអីតាមរបស់ ប្រជាជនចាស់ៗ ខ្នុរ ខ្ទះអីខ្នុរហូបមិនដឹងទាំងអស់នោះផង ។ ហូបតាមចិត្ត ចង់ហូបប៉ុន្មានហូបទៅ ។

សុវណ្ណៈ សូមកាត់បន្ដិចពូ! ចុះពេលបច្ចុប្បន្ននេះពូ មានអីដែលពូពេញចិត្ត ហើយមានអ៊ីដែលពូមិនពេញចិត្តខ្លះទេនៅពេលដែលបច្ចុប្បន្ននេះ?

ភីម: ទេ! ខ្ញុំគ្មានអីដែលថាពេញចិត្ត ឬមិនពេញចិត្តទេ បាទ! ពេញចិត្តទាំងអស់ហ្នឹង និងគ្មានអីដែលមិនពេញចិត្តហ្នឹងវាទេ ។

សុវណ្ណៈ ចំណុចណាដែលពូពេញចិត្តខ្លះ?

ភីម: ពេញចិត្តខ្ញុំបញ្ហាផ្លូវ និយាយរួមការកាសាងអ្វីទាំងអស់ទៅណា ។

សុវណ្ណៈ ចុះមានចំណុចអីដែលមិនពេញចិត្តខ្លះទេពេលបច្ចុប្បន្នការរស់នៅនេះ?

ភីម: តាមមើលទៅដូចជាគ្មានអីទេ ការរស់នៅយើង ប៉ុន្តែខ្ញុំវាពិបាកថា ដូចថាខ្ញុំសព្វថ្ងៃ គ្មានគិតអីទេ ព្រោះថាជីវិតរស់នៅយ៉ាងណា ប្រឡប់យ៉ាងណា អ្នកធ្វើអីតែប៉ុណ្ណឹង ខ្ញុំខ្វិលគិតអីណាស់ បើចំនាស់នេះហើយណា៎ មិនដឹងជាគិតយ៉ាងម៉េចទេ ។ គិតតែធ្វើទៅ យ៉ាងម៉េច គ្រាន់តែឲ្យតែគេមើលទៅសមរម្យហ្នឹងភ្នែកគេមើលទៅ គេមើលក្រៅខាងទៅសមរម្យប៉ុណ្ណឹងបានហើយ ។

សុវណ្ណៈ ចេះ! ពូសព្វថ្ងៃពូ អ្នកជិតខាងគ្នា ច្រើនតែនិយាយអីជាមួយគ្នាខ្លះពូ ពិភាក្សារឿងនេះរឿងនោះ ពីភាក្សារឿងអី?

ភីម: បើថាខ្ញុំវិញ ការរកស៊ីវិញ ខ្ញុំគ្មានស្អីទេ បាទ! ជាពិសេសចម្ការ បានប៉ុន្មានខែទៅ ស្រូវបានប៉ុន្មាន អាខាងនេះបានប៉ុន្មាន ខែជួបគ្នា មានខែអី មានតែស្រូវតែម្តង បានប៉ុន្មានបានប៉ុណ្ណឹងហើយ ។

សុវណ្ណៈ ហើយក្រៅពីការ ពិភាក្សាគ្នារឿង រកស៊ីធ្វើការមាននិយាយរឿងអីផ្សេងទៀតទេ?

ភីម: ទេ! ដូចគ្មានទេ ។ គ្មាននិយាយអីទេ រឿងផ្សេងៗ ។

សុវណ្ណៈ រឿងបុណ្យទាន ចូលឆ្នាំ?

ភីម: មានអាចឹងៗណា ។ បាទ! អានិយាយរឿង អាដែងយើងបុណ្យទាន ចូលឆ្នាំ ដាច់ឆ្នាំដាច់ខែចឹងណាបាទ! វាចេញមកនិយាយ មិនមែនអត់ទេ ។

សុវណ្ណៈ ហើយយើងនិយាយគ្នាទៅ យើងពិភាក្សាទាំងសប្បាយចិត្ត ឬក៏មិនសប្បាយចិត្តពូ?

ភីម: ទេ!និយាយថាម៉េចទេ បើមិនសប្បាយវាយ៉ាងម៉េចកើត ។ និយាយហើយ យើងសើចណា ។

សុវណ្ណៈ ខុសប្លែកពីអាកាលយើងនៅពេលវត់តស៊ូណ៎ពូ នៅក្នុងរបបបីឆ្នាំណាពូ ដែលពូមានការពិភាក្សាចឹងអត់ទេពូ និយាយរកគ្នា ទាក់ទងគ្នាអីចឹងទេពូ?

ភីមៈ ពិភាក្សាដូចគ្នា ដូចនេះហើយបីឆ្នាំ យើងនិយាយផ្សេងណា កាលលំបាកផ្សេងចេះមួយចុះមួយ សម្ងាប់ដោយកាលបងប្អូនគេយ៉ាងម៉េចៗ ហើយមកសម័យនេះវាយ៉ាងម៉េច ស្រួលយ៉ាងម៉េច រកស៊ីយ៉ាងម៉េច ស្រួលអីយ៉ាងម៉េចៗ មើលឃើញហើយគ្រប់គ្នាចឹងណា ។

សុវណ្ណៈ ហើយយើងនិយាយគ្នា និយាយទាំងការភ័យខ្លាច ឬក៏យើងនិយាយទាំងមិនសប្បាយចិត្ត ឬក៏មានទុកព្រួយអីណាពេលនោះ ។

ភីមៈ ទេ! ខ្ញុំគ្មានទុកព្រួយអីទេ និយាយដូវល្អ និយាយឲ្យត្រឹមត្រូវសប្បាយចិត្ត និយាតែដូវល្អ មិននិយាយបោកប្រាស់ណា ។

សុវណ្ណៈ ខ្ញុំចង់និយាយថា ពេលពូពិភាក្សាគ្នាទៅ ពិភាក្សាទាំងទុកព្រួយ ឬដោយសារភ័យខ្លាច ឬក៏យ៉ាងម៉េចពូក្នុងរបបហ្នឹង?

ភីមៈ កាលពីជំនាន់នោះយើងពិភាក្សាគ្នាទៅវាខ្លាចដែលណា សម័យបីឆ្នាំ នោះគេពិភាក្សាស្ងាត់និយាយគ្នាដូចថាស្គាល់នរណាមួយ យើងនិយាយគ្នា ឥលូវដូចថាយើងបាននិយាយគ្នាស្ងាត់ៗទេណា ដល់ពេល(ស្ដាប់ពុំបាន) ក្នុងជំនាន់បីឆ្នាំ ។

សុវណ្ណៈ ខ្លាចគេយកទៅធ្វើបាប?

ភីមៈ បាទ! ខ្លាចគេយកទៅធ្វើបាប ទោះបីយប់ក៏អត់ហាននិយាយដែរ គេស្ដាប់ក្រោមផ្ទះ ។

សុវណ្ណៈ ចុះពេលមករត់គស៊ូភ្នំនេះ ហើយហ្នឹងរត់គស៊ូនៅតំបន់នេះយើង ពិភាក្សាគ្នា មានចឹងដែលអត់ពូ? គេទាក់ទងគ្នា និយាយគ្នាអីខ្លះទេ?

ភីមៈ មិនមែនទេ! ដល់លើភ្នំនេះទេ ។

សុវណ្ណៈ ហើយយើងនិយាយអីគេពេលទៅលើភ្នំ ពេលនៅគស៊ូ?

ភីមៈ ពេលដែលពីលើភ្នំនោះ?

សុវណ្ណៈ បាទ!

ភីមៈ យើងគស៊ូយើង៣ឆ្នាំ?

សុវណ្ណៈ ខ្ញុំចង់និយាយថា ពេលយើងគស៊ូ រត់ទៅ១០០១ រត់គស៊ូនៅខាងអូរស្មាយ អូរអីកាលហ្នឹងតំបន់យើង អត់ទាន់ធ្វើសមាហរណកម្មណា ។ យើងច្រើននិយាយរឿងជាមួគ្នាហ្នឹង យើងនិយាយទាំងភ័យខ្លាច ឬយើងនិយាយរឿងអីគេ ពេលហ្នឹងពូ?

ភីមៈ ទេ! កាលហ្នឹងយើងនិយាយ គ្មានភ័យខ្លាចអីទេ បើយើងនិយាយគេបីឆ្នាំនោះក៏គ្មាននរណាគេធ្វើអីមួយជំនាន់នោះណា ។ និយាយរឿងបីឆ្នាំនោះក៏គ្មាននរណាធ្វើអី អត់នរណាធ្វើអីកើតទេ

វាយនៅកំពង់តែប្រទះប្រទាញគ្នា ប្រុងតែវាយគ្នា ។ កម្លាំងនោះកម្លាំង បីឆ្នាំនេះ បីឆ្នាំចុះ ទាំងអស់នោះស្រេចតែឯងទេចឹង ។

សុវណ្ណៈ ពេលយើងនៅតស៊ូនៅនេះ ចង់ធ្វើបុណ្យធ្វើទាន យើងធ្វើម៉េចទៅពូ ទៅវត្តទៅវាអី?

ភីមៈ កាលពីយើងតស៊ូ?

សុវណ្ណៈ ពេលយើងតស៊ូ នៅលើភ្នំ និងពេលចុះមកក្រោម កំឡុងពេលហ្នឹង យើងទៅវត្តទៅវាទេ ពេលហ្នឹង?

ភីមៈ អត់មានទេ! អត់មានទាំងលោកផង គ្មានស្អីផង ។

សុវណ្ណៈ ចុះបើយើងចង់ធ្វើបុណ្យធ្វើទាន ធ្វើយ៉ាងម៉េចទៅ?

ភីមៈ ទេ! បើប្រពន្ធកូន ឧទាហរណ៍ថាបើមានស្លាប់មនុស្សយើងធ្វើបុណ្យ យើងហៅគ្នានោះចាស់ មកទៅ ។

សុវណ្ណៈ ចូលឆ្នាំ ភ្ជុំអីនោះ?

ភីមៈ ចូលឆ្នាំ ភ្ជុំអីក៏សែនដូចគ្នា ។

សុវណ្ណៈ មានធ្លាប់ទៅវត្តទៅវាទេ?

ភីមៈ អត់មានវត្តទេ កាលនោះគ្មានវត្តទេ បើថាភ្ជុំៗដូចគ្នា ហៅជីដូនជីតា ហៅឯម្តង អញម្តង គ្រប់ផ្ទះទៅណា ។ បាទ! ថ្ងៃណាគេធ្វើទៅ ហើយថ្ងៃណាក៏អត់ទៅ ប៉ុនោះឯង ធ្វើទាំងអស់គ្នា នោះ ។ គ្រាន់តែខ្ញុំ ម៉េចក៏បានបែកផ្លូវ(ស្តាប់ពុំបាន) ស្ងោរចេក នំអន្សម សែនដូនតាទៅ ។

សុវណ្ណៈ ចុះពេលគេចាប់មានទៅវត្ត ទៅវា គេមានចាប់ពីពេលណាមកដែរ?

ភីមៈ ទេ! កាលផ្តាច់ខ្លួនមកពុំមានទេណា ដល់ក្រោយមក(ស្តាប់ពុំបាន) ទើបមានជាហែរៗមកណា បាទ! ជាវត្តជាផ្លូវអី ហែរៗមក ទើបមានទាល់តែឥលូវណា ។

សុវណ្ណៈ ក្រៅពីសមាហរណកម្ម៩៨ មកពូ?

ភីមៈ បាទ!

សុវណ្ណៈ ចឹងចាប់ពីហ្នឹងមកយើង មានធ្វើបុណ្យធ្វើទានទៅវត្តអីត្រឹមត្រូវណាពូហ៎?

ភីមៈ មានកាលនោះ ។

សុវណ្ណៈ ដល់ពេលសព្វថ្ងៃ ពូកាន់សាសនាអីគេ?

ភីមៈ ខ្មែរ ខ្ញុំមានអីទេ ។

សុវណ្ណៈ តែសាសនាខ្មែរ! សាសនាព្រះពុទ្ធ ឬសាសនាអីផ្សេង?

ភីមៈ ខ្ញុំមិនដឹងព្រះពុទ្ធ មិនដឹងស្អីទេនោះ ។

សុវណ្ណៈ ប៉ុន្តែ ទៅវត្តទៅវាអីគេដែរ?

ភឹមៈ បាទ!

សុវណ្ណៈ ទៅវត្ត មានទៅធ្វើបុណ្យអីគេ វត្តហ្នឹង?

ភឹមៈ ទេ! អារឿងវត្តអីហ្នឹង បុណ្យទៅចូល បើថាទៅដាក់បាត ទៅវត្ត ទៅវាអីទៀត ទៅសាសនាទៅណាទេ ។ ខ្ញុំអត់យល់ដែរហ្នឹងណា មិនដឹងយេស៊ូ មិនដឹងសាសនាណាទេ ប៉ុន្តែវត្តទាំងអស់គ្នា ភ្លុកទឹក ភ្លុកភូមិណា ។

សុវណ្ណៈ ចេះតែទៅធ្វើបុណ្យ ធ្វើទានទៅពូ?

ភឹមៈ ចុះគេទៅ យើងទៅធ្វើតែម្តង?

សុវណ្ណៈ យកចង្ហាន់ប្រគេនលោក ហ៎ពូ?

ភឹមៈ យកចង្ហាន់ ជួនណាទៅដើរលេងខ្លះទៅណា ។

សុវណ្ណៈ ហើយសម្រាប់ខ្លួន ពូផង ពូធ្លាប់ឆ្លងកាត់សង្គ្រាមកចឹងណា ពូយល់ឃើញថា សង្គ្រាមវាយ៉ាងម៉េចដែរពូ?

ភឹមៈ សង្គ្រាមនេះ! រឿងសង្គ្រាមយើង ពីជំនាន់មុនគស៊ូ ពីជំនាន់មុនមក ។

សុវណ្ណៈ សម្រាប់ខ្លួនពូធ្លាប់ ឆ្លងកាត់ហើយចឹង តើពូធ្លាប់គិតថាសង្គ្រាមធ្លាប់វាផ្តល់ផលប្រយោជន៍ទេ?

ភឹមៈ អារឿងសង្គ្រាមនេះ គឺគ្មានផលប្រយោជន៍ ណាមួយខ្លួនយើងនោះទេ យើងមានតែហិនហោច មានតែស្លាប់មនុស្ស ណ៎សង្គ្រាម! ទោះបីថាសង្គ្រាមបើថាសង្គ្រាមហើយ ហិនហោចផង ហើយក្នុងការដែររស់នៅ វាពិបាកផង ទោះបីជាបុគ្គលគ្មានហូបផងទេ អារឿងរបស់ទាហាន អារឿងវាយគ្នានេះ វាលំបាកបំផុតៗ គ្មានរឿងអីទេ ។

សុវណ្ណៈ សព្វថ្ងៃនេះ បើស្រុកទេស វាត្រូវការពូត្រលប់ទៅធ្វើទាហាន ទៅច្បាំងទៅអីវិញ ពូទៅចូលរួមទៀតទេពូ?

ភឹមៈ អ៊ូ! ខ្ញុំទៅលែងរួចហើយ ចប់ហើយ ឈប់ចង់ហើយ ទោះបីជា! ចំនាស់ប៉ុណ្ណេះហើយ ទៅណារួច ។

សុវណ្ណៈ ប៉ុន្តែចិត្តពូចង់ទៅទៀត ឬក៏យ៉ាងម៉េចដែរ ឬក៏អត់ចង់ធ្វើទេ?

ភឹមៈ ទេ! បើនៅដើងល្អដូចគេ បើផែនការឲ្យទៅ ក៏ទៅដូចគ្នា ។

សុវណ្ណៈ មូលហេតុអ្វីបានជាពូចង់ទៅទៀត?

ភឹមៈ ទេ! បើគេឲ្យទៅ ។ បើគេមិនទៅ គេធ្វើបាត់ ។

សុវណ្ណៈ	គេសួរពូស្ម័គ្រចិត្ត ចឹងណា តើពូព្រម ឬក៏មិនព្រម?

ភីមៈ	បើថាស្ម័គ្រចិត្ត ខ្ញុំមិនទៅទេ ។ ខ្ញុំឆ្អែតហើយ អារឿងទាហាននោះ បាទ! ខ្ញុំឆ្អែតហើយ ។ និយាយរួមតាំងពី មិនមែនយូរឆ្នាំទេ ទើប៧៩ រហូតដល់សម្តេចយើងបានខ្ញុំឈប់កាន់កាំភ្លើង ។

សុវណ្ណៈ	ហើយពូចេះ សព្វថ្ងៃគេនៅតាមសាលារៀន គេមានដាក់ឲ្យក្មេងៗរៀន និងរឿងរ៉ាវដំបូងខ្មែរក្រហមណាពូ ពូនៅតាមសាលារៀន តាមវិទ្យាល័យអី តើពូគិតថា ក្មេងៗទាំងអស់ហ្នឹងគួតែរៀន ឬរៀនពីរឿងរ៉ាវរបបខ្មែរក្រហមទេពូ?

ភីមៈ	ទេ! គួរៀនដែរណ៎ ។ រៀនមើលប្រវត្តិសាស្ត្រ និយាយអាមួយជំនាន់ណាៗ ។ មួយជំនាន់លំបាកយ៉ាងម៉េចៗ ខ្មែរក្រហមវាយ៉ាងម៉េច គេជំនាន់បីឆ្នាំវាយ៉ាងម៉េចៗណ៎ យើងមើលឃើញ យើងដឹងហើយ ពួកក្មេងក្រោយវាអត់ដឹងទេ អាក្មេងក្រោយនោះបាទ! ដឹងតែមនុស្សជំនាន់មុនទេ សម័យបីឆ្នាំវាយ៉ាងម៉េចៗ វាពិបាកយ៉ាងម៉េច វាព្រួយឈឺថ្កាត់យ៉ាងម៉េច អានោះគេដឹង បើក្មេងសាក្រោយវាពុំដឹងទេ ។

សុវណ្ណៈ	ហើយពូគឹតថាការរៀនសូត្ររបស់ក្មេងៗ ពីរឿងរ៉ាវរបបខ្មែរក្រហមវាសំខាន់ ឬក៏មិនសំខាន់ទេ?

ភីមៈ	កាលនោះ! ទេ ខ្ញុំមិនសំខាន់ទេ ។

សុវណ្ណៈ	ខ្ញុំចង់និយាយថាចេះ ឥលូវក្មេងៗរៀនរបបខ្មែរក្រហមហ្នឹងណា៎! ដែលពូគិតថាគួរៀនហ្នឹងគិតថាការៀនសូត្រហ្នឹងវាសំខាន់ ឬក៏មិនសំខាន់ទេ?

ភីមៈ	រឿងរ៉ាវនោះខ្ញុំ ថាដូចជាមិនសំខាន់ទេរបបខ្មែរក្រហមណាស់ ។ បើកាលរបបខ្មែរក្រហមយើងរៀនសូត្រពីអារបបហ្នឹងនោះ របបខ្មែរក្រហមដែលសម្លាប់មនុស្ស ព្រោះយើងសម្លាប់ដូចយើងចាប់គក្អាណា ។

សុវណ្ណៈ	ដូចចេះ ឥលូវក្មេងៗកំពុងតែរៀន រឿងរ៉ាវរបបខ្មែរក្រហមនៅតាមសាលារៀនណ៎ តើពូគិតថាការរៀនសូត្រហ្នឹងវាសំខាន់ទេ?

ភីមៈ	អារៀនរបបនេះ?

សុវណ្ណៈ	បាទ!

ភីមៈ	រៀនដើម្បីឲ្យវាយល់ ឲ្យវាយល់ពីរបបខ្មែរក្រហមណ៎ របបខ្មែរក្រហមវាយ៉ាងម៉េច ហើយរបបសង្គមវាយ៉ាងម៉េច វាត្រូវយល់ចឹង ។ បើអារបបខ្មែរក្រហម វានៅដើម្បីឲ្យវាមើលដើម្បីឲ្យវាយ៉ាងម៉េច ព្រោះវាអត់ដឹង វាអត់ដឹងជំនាន់មុនមក វាយ៉ាងម៉េច ដូនការវាដឹងថា

យល់កាប់សម្លាប់ចេះចុះៗ ។ របបនេះធ្វើចេះ របបនោះធ្វើចុះ សង្គមនេះធ្វើចេះ ធ្វើចុះ វាដឹងទាំងអស់ណា៎ ។

សុវណ្ណៈ ពូមានដែលនិយាយរឿងប្រវត្តិ តស៊ូរបស់ពូប្រាប់កូនៗចៅៗទេ?

ភីមៈ ហ៊ូ! រឿងផ្ទាល់ខ្លួន ខ្ញុំនិយាយប្រាប់ខ្ទេចគ្មានសល់ទេ ។

សុវណ្ណៈ ច្រើនតែនិយាយរឿងអីប្រាប់?

ភីមៈ ការលំបាក តស៊ូ កាលជំនាន់៣ឆ្នាំ មានការលំបាកយ៉ាងម៉េច ការហូបចុកយ៉ាងម៉េច ហើយជំនាន់តស៊ូព្រៃ ហូបទីនេះយ៉ាងម៉េច ទីនោះយ៉ាងម៉េច ខ្ញុំនិយាយអស់ហើយ ។

សុវណ្ណៈ ពូនិយាយប្រាប់ចឹង កូនថាម៉េច?

ភីមៈ មានថាម៉េច បើយើងនិយាយតស៊ូ ការលំបាកបីឆ្នាំនោះ ដូចថាចឹង វាថាទៅណា៎ ដឹងតែពុកឯង ខ្ញុំមិនដឹងផង មិនដឹងលំបាកយ៉ាងម៉េច ដឹងចេះតែថាលំបាកៗ ខ្ញុំមិនដឹងដែរ ដល់សម័យនេះហើយ ។

សុវណ្ណៈ ពូ! ខ្ញុំដូចជាអស់សំណួរសួរពូដែរ ហើយពូមានអីចង់បន្ថែមទៀតទេពូ?

ភីមៈ ទេ! ខ្ញុំដូចគ្មានអីដែរទេហ្នឹងណា បើសួរចេះទេទៅហើយ ។

សុវណ្ណៈ ចឹងខ្ញុំអរគុណពូច្រើនដែលផ្ដល់បទសម្ភាសន៍ណាពូណា អរគុណ ។

«ចប់»